**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងសេវាឥណទាន
# របស់ធនាគារពាណិជ្ជ

ស្រាវជ្រាវថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **ហ៊ីម ផាន់ណារ៉ុង**
**សៀម ចាន់សម្ព័ស**

សាស្ត្រាចារ្យណែនាំ៖
លោក **ឈាង ហ៊ុយ**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ហ៊ីម ផាន់ណារ៉ុង** និង **សៀម ចាន់សម្ភ័ស** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រជំនាញ **ធនាគារ និង ហិរញ្ញវត្ថុ** ឆ្នាំទី៤ ក្រុម B4A1 ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

-លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណដ៏ធំធេងនៃកូន ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ និង បានបីបាច់ថែរក្សានិងផ្គត់ផ្គង់តាំងពីតូចរហូតមកដល់ពេលធំដឹងក្តីទាំងសម្ភារៈសិក្សានិងថវិការព្រមទាំងការ ជម្រុញលើកទឹកចិត្តទាំងផ្លូវកាយនិងផ្លូវចិត្តដល់រូបកូន។ដោយសារការសណ្តោសប្រោសប្រណីនិងទឹកចិត្តដ៏ ប្រពៃរបស់លោកទាំងពីរទើបកូនអាចក្លាយជាមនុស្សដ៏ល្អរស់នៅក្នុងសង្គម និងទទួលបានការសិក្សាអប់រំដ៏ល្អ ប្រពៃ។

-ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យនៃសាកល វិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានបង្ហាត់បង្រៀននិងអប់រំណែនាំដល់រូប យើងខ្ញុំឲ្យទទួលបានចំណេះដឹងថ្មីៗសម្រាប់ជាបទពិសោធន៍ការងារនៅពេលខាងមុខនិងពេលអនាគតហើយជា គំរូដ៏ល្អមួយសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

-លោកគ្រូសាស្រ្តាចារ្យ **ឈាង ហ៊ុយ** ដែលបានចំណាយកម្លាំង និងពេលវេលាដ៏មានតម្លៃក្នុងការ ណែនាំ និងផ្តល់យោបល់ល្អៗ ព្រមទាំងកែសម្រួលនូវកំហុសឆ្គងទាំងឡាយដែលកើតមានក្នុងកិច្ចការរបស់ យើងខ្ញុំឲ្យមានភាពប្រសើរនិងទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពដឹងគុណចំពោះអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋ កិច្ច សូមជួបតែសំណាងល្អ សុខភាពល្អ សុភមង្គល និងប្រកបការងារអ្វីទទួលបានជោគជ័យលើគ្រប់ភារកិច្ច។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១៤ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោយពីបានឆ្លងកាត់ការសិក្សា និងបណ្តុះបណ្តាលជំនាញនេះ អស់រយៈពេល៤ឆ្នាំកន្លងមក ធ្វើឱ្យក្រុមយើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនដែលទាក់ទងនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ។ ជាក់ស្តែងក្នុងឆ្នាំទី៤នេះ យើងខ្ញុំបានធ្វើការជ្រើសរើសយកការសរសេរសារណាមកធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើការបញ្ចប់ថ្នាក់បរិញ្ញាប័ត្ររបស់យើងក្នុងជំនាញធនាគារ និងហិរញ្ញវត្ថុនេះ។ ដោយការសិក្សាត្រឹមតែទ្រឹស្តីដែលទាក់ទងទៅនឹងធនាគារនិងហិរញ្ញវត្ថុគឺពុំទាន់គ្រប់គ្រាន់នោះទេ ប៉ុន្តែវាក៏ត្រូវមានការអនុវត្តជាក់ស្តែងផងដែរទើបធ្វើឲ្យចំណេះដឹងនិងជំនាញដែលបានសិក្សាកន្លងមកទទួលបានជោគជ័យនិងមានប្រសិទ្ធភាព។

ដោយមើលឃើញពីគុណតម្លៃនិងអត្ថប្រយោជន៍នៃវិស័យធនាគារទើបក្រុមយើងខ្ញុំបានជ្រើសរើសប្រធានបទមួយដើម្បីយកមកធ្វើការបកស្រាយដែលទាក់ទងទៅនឹងការគ្រប់គ្រងសេវាឥណទានរបស់ធនាគារពាណិជ្ជដើម្បីឲ្យមានភាពងាយស្រួលក្នុងការសិក្សានិងស្វែងយល់ជាងមុន។

សង្ឃឹមថាកិច្ចការស្រាវជ្រាវនេះអាចជួយផ្តល់ជាភាពងាយស្រួលក្នុងការសិក្សារបស់សិស្សនិស្សិត និងសាធារណជនដែលមានបំណងចង់យល់ពីការគ្រប់គ្រងសេវាឥណទានរបស់ធនាគារពាណិជ្ជ។ ក្រុមយើងខ្ញុំរងចាំជានិច្ចរាល់ការរិះគន់ដើម្បីស្ថាបនា ជាបន្ថែមទៀតពីសំណាក់លោក-លោកស្រី សាស្ត្រាចារ្យក្នុងទិសដៅកែលម្អនូវរាល់ខ្លឹមសារក្នុងកិច្ចការស្រាវជ្រាវនេះបន្ថែមទៀត ដើម្បីឲ្យកិច្ចការស្រាវជ្រាវនេះរឹងរឹតតែមានភាពពេញលេញនិងសមស្របតាមប្រធានបទ។

ជាទីបញ្ចប់ ក្រុមយើងខ្ញុំសូមជូនពរដល់លោក លោកស្រីសាស្ត្រាចារ្យនិងសិស្ស និស្សិតទាំងអស់ដែលបានយកចិត្តទុកដាក់តាមដាននូវកិច្ចការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះ សូមឲ្យជួបតែសំណាងល្អ សុខភាពល្អ សុភមង្គលនិងជោគជ័យលើគ្រប់ភារកិច្ច។

# មាតិកា

**ទំព័រ**

បញ្ជីតារាង ........ vii

បញ្ជីឧបសម្ព័ន្ធ ........ viii

## សេចក្តីផ្តើម

១.លំនាំបញ្ហា ........ ១

២.ចំណោទបញ្ហា ........ ១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥.វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

  ៥.១.ទិន្នន័យបន្ទាប់បន្សំ ........ ២

  ៥.២.ការវិភាគទិន្នន័យ ........ ២

៦.សារៈសំខាន់នៃការស្រាវជ្រាវ........ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី១

## រំលឹកទ្រឹស្តី

១.១.ស្ថានភាពទូទៅរបស់ធនាគារពាណិជ្ជ........ ៤

  ១.១.១.ប្រវត្តិធនាគារពាណិជ្ជ ........ ៤

  ១.១.២.និយមន័យ........ ៧

  ១.១.៣.តួនាទីរបស់ធនាគារពាណិជ្ជ ........ ៧

    ១.១.៣.១.អន្តរការី ........ ៧

១.១.៣.២.ទូទាត់ ........ ៧

១.១.៣.៣.អ្នកធានា ........ ៧

១.១.៣.៤.ភ្នាក់ងារ ........ ៧

១.១.៣.៥.ទីប្រឹក្សាលើការសន្សំ ........ ៨

១.១.៣.៦.គ្រប់គ្រងហានិភ័យ ........ ៨

១.១.៣.៧.ថែរក្សាទ្រព្យសម្បត្តិមានតម្លៃ ........ ៨

១.១.៣.៨.អនុវត្តគោលនយោបាយ ........ ៨

១.២.សេវាកម្មទូទៅរបស់ធនាគារពាណិជ្ជ ........ ៨

១.២.១.សេវាឥណទាន ........ ៨

១.២.១.១.និយមន័យ ........ ៨

១.២.១.២.ប្រភេទនៃសេវាកម្មឥណទាន ........ ៨

១.២.២.សេវាទទួលប្រាក់បញ្ញើ ........ ១០

១.២.២.១.និយមន័យ ........ ១០

១.២.២.២.ប្រភេទនៃប្រាក់បញ្ញើ ........ ១០

១.២.៣.សេវាផ្ទេរប្រាក់ ........ ១១

១.២.៣.១.និយមន័យ ........ ១១

១.២.៣.២.ប្រភេទសេវាផ្ទេរប្រាក់ ........ ១១

១.២.៤.សេវាផ្សេងទៀត ........ ១២

១.៣.ដំណើរការនៃការគ្រប់គ្រងឥណទាន ........ ១២

១.៣.១.ការផ្សព្វផ្សាយ ........ ១២

១.៣.២.ការជ្រើសរើសសំណើរសុំដំបូង ........ ១២

១.៣.៣.ការស៊ើបអង្កេតឥណទាន ........ ១៣

១.៣.៤.ការសម្រេចចិត្ត ............ ១៤
១.៣.៥.ការត្រួតពិនិត្យគណនី ............ ១៥
១.៣.៦.ការប្រមូលឥណទាន ............ ១៥
១.៤.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ............ ១៥
១.៥.ហានិភ័យឥណទាន ............ ១៦
១.៥.១.មូលហេតុដែលបណ្ដាលឲ្យមានហានិភ័យ ............ ១៦
១.៥.២.ផលប៉ះពាល់បណ្ដាលមកពីហានិភ័យ ............ ១៨
១.៥.៣.យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ............ ១៩
១.៥.៤.ដំណោះស្រាយឥណទានមានបញ្ហា ............ ១៩
១.៦.សារៈសំខាន់របស់ធនាគារពាណិជ្ជ ............ ១៩

## ជំពូកទី២

## លក្ខណៈទូទៅនៃការបង្កើតធនាគារពាណិជ្ជ

២.១.លក្ខខណ្ឌតម្រូវចំពោះភាគទុនិកនិងគណៈគ្រប់គ្រង ............ ២១
២.១.១.ភាគទុនិក ............ ២១
២.១.១.១.ការព្រមព្រៀងរបស់ភាគទុនិក ............ ២១
២.១.១.២.អត្តសញ្ញាណរបស់ភាគទុនិក ............ ២២
២.១.២.គណៈគ្រប់គ្រង ............ ២៣
២.១.២.១.ក្រុមប្រឹក្សាភិបាល ............ ២៣
២.១.២.២.គណៈប្រតិបត្តិ ............ ២៥
២.១.២.៣.គណៈកម្មការជំនាញ ............ ២៥
២.១.២.៤.គណៈកម្មការគ្រប់គ្រងហានិភ័យ ............ ២៦
២.២.នីតិវិធីនៃការបង្កើត ............ ២៦

២.២.១.លក្ខខណ្ឌក្នុងការទទួលបានអាជ្ញាប័ណ្ណ ....................................................................២៦
២.២.១.១.ការដាក់ពាក្យសុំនិងការផ្តល់អាជ្ញាប័ណ្ណ .............................................................២៧
២.២.១.២.ដើមទុននិងប្រាក់បម្រុងកាតព្វកិច្ច .....................................................................២៨
២.២.២.សោហ៊ុយលើសេវាអាជ្ញាប័ណ្ណ.......................................................................................២៨
២.២.២.១.តម្លៃសិក្សាអាជ្ញាប័ណ្ណ...............................................................................................២៨
២.២.២.២.សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ....................................................................................២៨
២.៣.ប្រភពមូលនិធិ ...................................................................................................................២៩
២.៣.១.ប្រភពពីបញ្ញើ ..............................................................................................................២៩
២.៣.១.១.ប្រាក់បញ្ញើតាមតម្រូវការ.......................................................................................២៩
២.៣.១.២.ប្រាក់បញ្ញើសន្សំ.......................................................................................................២៩
២.៣.១.៣.ប្រាក់បញ្ញើមានកាលកំណត់...................................................................................២៩
២.៣.២.ប្រភពមិនមែនបញ្ញើ.....................................................................................................២៩
២.៣.២.១.កម្ចីពីធនាគារជាតិ .....................................................................................................២៩
២.៣.២.២.ស្ថាប័នហិរញ្ញវត្ថុដទៃទៀត.......................................................................................២៩
២.៣.២.៣.កម្ចីពីទីផ្សារមូលធន ...............................................................................................២៩
២.៣.៣.មូលធនផ្ទាល់ខ្លួនរបស់ភាគទុនិក ..................................................................................៣០
២.៤.ធនាគារពាណិជ្ជក្នុងប្រទេសកម្ពុជា.....................................................................................៣០

## ជំពូកទី៣

## ការគ្រប់គ្រងឥណទាន

៣.១.គោលបំណងនៃការគ្រប់គ្រង ..............................................................................................៣១
៣.២.អតិថិជនគោលដៅ.............................................................................................................៣១
៣.៣.សារៈសំខាន់នៃការគ្រប់គ្រង ...............................................................................................៣១

៣.៤.នីតិវិធីនៃការគ្រប់គ្រង ............ ៣២

៣.៤.១.ការដាក់ពាក្យសុំចុះឈ្មោះ ............ ៣២

៣.៤.២.ការចុះអង្កេត និងវាយតម្លៃ ............ ៣២

៣.៤.៣.ការអនុម័ត ............ ៣៤

៣.៤.៤.ការរៀបចំឯកសារ ............ ៣៤

៣.៤.៥.ការបញ្ចេញឥណទាន ............ ៣៥

៣.៤.៦.ការតាមដានប្រាក់សំណង និងការប្រមូលសំណង ............ ៣៥

៣.៤.៧.ការយកឥណទានសារឡើងវិញ ............ ៣៥

៣.៤.៨.ការគ្រប់គ្រងស្ថានភាពឥណទានមានបញ្ហា ............ ៣៦

៣.៥.រូបិយប័ណ្ណ ទំហំឥណទាន និងអត្រាការប្រាក់ ............ ៣៦

៣.៦.របៀបសងត្រឡប់ ............ ៣៧

៣.៧.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ............ ៣៧

៣.៧.១.ការធ្វើចំណាត់ថ្នាក់ឥណទាន ............ ៣៧

៣.៧.២.សំវិធានធន ............ ៣៩

៣.៨.ហានិភ័យឥណទាន ............ ៤០

៣.៨.១.មូលហេតុដែលនាំឲ្យមានហានិភ័យ ............ ៤០

៣.៨.២.វិធីសាស្រ្តកាត់បន្ថយហានិភ័យ ............ ៤១

៣.៨.៣.ដំណោះស្រាយឥណទានមានបញ្ហា ............ ៤១

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន ............ ៤២

២.អនុសាសន៍ ............ ៤២

## ឯកសារយោង

# ឧបសម្ព័ន្ធ

# បញ្ជីតារាង

តារាងទី៣.១៖ ការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ......................................................................៣៨

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ជីវប្រវត្តិ និងការសាកសួរព័ត៌មានអំពីឯកត្តជន ឬជនដែលបម្រុងក្លាយទៅជា គណៈនាយក ភាគទុនិក នាយកចាត់ការរបស់ធនាគារពាណិជ្ជ ...........................................................................

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

ក្រោយពីបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃអស់រយៈពេលជាច្រើនទសវត្សរ៍ និងការទទួលបានសុខសន្តិភាពពេញលេញយើងសង្កេតឃើញថាការជម្រុញប្រទេសជាតិឲ្យមានការរីកចម្រើនលូតលាស់ និងជឿនលឿនទៅមុខគឺជាកត្តាមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសឲ្យមានភាពប្រសើរឡើង។ វិស័យសេដ្ឋកិច្ចជាវិស័យអាទិភាពមួយក្នុងការស្តារនិងអភិវឌ្ឍប្រទេសជាតិ និងដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងប្រទេសកម្ពុជាក៏មាននិន្នាការដូចេ្នះដែរគឺរាជរដ្ឋាភិបាលបានស្វះស្វែងរកមធ្យោបាយ និងវិធានការជាច្រើនក្នុងការជម្រុញសេដ្ឋកិច្ចប្រទេសកម្ពុជាឲ្យមានភាពរីកចម្រើនទៅមុខ។ ដោយឈរលើចក្ខុវិស័យក្នុងការលើកស្ទួយសេដ្ឋ-កិច្ច រាជរដ្ឋាភិបាលបានបើកទីផ្សារសេរីក្នុងការទាក់ទាញវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសឲ្យចូលមកវិនិយោគតាមរយៈការអភិវឌ្ឍដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ វិស័យអប់រំ និងវិស័យជាច្រើនទៀតដែលក្នុងនោះក៏មានវិស័យធនាគារផងដែរ។ ដើម្បីគាំទ្រដល់វិនិយោគិនធ្វើការវិនិយោគក្នុងប្រទេសកម្ពុជារាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តដល់វិនិយោគិនតាមរយៈការបន្ធូរបន្ថយពន្ធ និងសន្តិសុខសង្គមផ្សេងៗ ដែលជួយលើកស្ទួយនិងទាក់ទាញចំណាប់អារម្មណ៍ឲ្យវិនិយោគិនឲ្យបានច្រើនជាបន្តបន្ទាប់ឥតឈប់ឈរជាពិសេសលើវិស័យធនាគារ។

ជាការពិតណាស់ វិស័យធនាគារជាវិស័យដ៏សំខាន់មួយដែលបានចូលរួមចំណែកក្នុងការ ជម្រុញសេដ្ឋកិច្ចឲ្យរីកចម្រើនតាមរយៈស្ថាប័នហិរញ្ញវត្ថុដូចជា ធនាគារពាណិជ្ជ ធនាគារវិនិយោគ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាដើម។

បច្ចុប្បន្នធនាគារគឺជាភ្នាក់ងារមួយដ៏សំខាន់ក្នុងការផ្តល់នូវសេវាកម្មជាច្រើនដូចជា ការទទួលប្រាក់បញ្ញើការផ្តល់កម្ចី និងសេវាផ្ទេរប្រាក់ជាដើម ដែលជាប្រភពចំណូលមួយដ៏សំខាន់ ហើយវាក៏ជួយលើកស្ទួយដល់ជីវភាពរបស់ប្រជាជនឲ្យមានការរីកចម្រើនតាមរយៈការបង្កើតឬពង្រីកមុខរបររបស់ខ្លួន។ ប៉ុន្តែប្រសិនបើប្រតិបត្តិការលើសេវាកម្មរបស់ខ្លួនពុំមានប្រសិទ្ធភាពនោះទេនឹងធ្វើឲ្យគ្រឹះស្ថានជួបនូវបញ្ហាហើយក៏អាចប៉ះពាល់ដល់សេដ្ឋកិច្ចជាតិផងដែរ។ ដោយយល់ឃើញពីបញ្ហា និងសារៈសំខាន់ទាំងនេះទើបមានប្រធានបទមួយស្តីពីការគ្រប់គ្រងឥណទាន របស់ធនាគារពាណិជ្ជត្រូវបានលើកយកមកសិក្សាស្រាវជ្រាវឲ្យកាន់តែស៊ីជំរៅនិងច្បាស់លាស់។

## ២.ចំណោទបញ្ហា

ដោយមើលឃើញពីការរីកចម្រើនលូតលាស់របស់ធនាគារពីមួយថ្ងៃទៅមួយថ្ងៃក្នុងការធ្វើប្រតិបត្តិការរបស់ខ្លួនក្នុងប្រទេសដែលជាលទ្ធផលនៃការបញ្ចេញឥណទានដែលជាប្រភពចំបងសម្រាប់ទ្រទ្រង់ប្រតិបត្តិការនិងសេដ្ឋកិច្ចជាតិ ជាពិសេសបានបង្កើតការងារដល់និស្សិតសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារតាមយៈប្រាក់ចំណូល

(ប្រាក់ខែ)តាមរយៈការបង្ហាញខាងលើ ថាតើធនាគារពាណិជ្ជមាននីតិវិធីនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងឥណទានបែបណា?

## ៣.គោលបំណង

គោលបំណងរួមលើការសិក្សាស្រាវជ្រាវនេះចង់ស្វែងយល់ពីការគ្រប់គ្រងឥណទានរបស់ធនាគារពាណិជ្ជ ដោយឡែកគោលបំណងជាក់លាក់នៃការសិក្សាស្រាវជ្រាវមានដូចខាងក្រោម៖

- ស្វែងយល់ពីលក្ខណៈទូទៅនៃការបង្កើតធនាគារពាណិជ្ជ
- ស្វែងយល់ពីផលិតផល និងសេវាកម្មទូទៅរបស់ធនាគារពាណិជ្ជ
- ស្វែងយល់ពីការគ្រប់គ្រងឥណទានរបស់ធនាគារពាណិជ្ជ

## ៤.ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ដោយបច្ចុប្បន្នក្នុងប្រទេសកម្ពុជាមានធនាគារពាណិជ្ជជាច្រើនកំពុងធ្វើប្រតិបត្តិការនៅតាមបណ្តាខេត្ត និងក្រុងជាមួយនឹងផលិតផល និងសេវាកម្មច្រើនប្រភេទរបស់ខ្លួន ដែលមិនអាចសិក្សាស្រាវជ្រាវបានទាំងអស់ទេ។ ការសិក្សាស្រាវជ្រាវផ្តោតដូចខាងក្រោម៖

- ធនាគារពាណិជ្ជទូទៅក្នុងប្រទេសកម្ពុជា
- ការគ្រប់គ្រងឥណទាន
- ទិន្នន័យឆ្នាំ២០២០

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើការគ្រប់គ្រងឥណទានត្រូវពឹងផ្អែកលើប្រភពទិន្នន័យ និងការវិភាគទិន្នន័យ ដូចខាងក្រោម៖

### ៥.១.ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យនេះជាទិន្នន័យដែលមានស្រាប់របស់ធនាគារដែលបានផ្សព្វផ្សាយ និងរក្សាទុក ដូចនេះការសិក្សាត្រូវប្រមូលទិន្នន័យបែបនេះរួមមាន៖

- ពីធនាគារស្តីពីឥណទាន និងព័ត៌មានផ្សេងៗ
- ឯកសារស្តីពីឥណទាន នៅក្នុងបណ្ណាល័យ
- តាមរយៈអ៊ីនធឺណេត និង គេហទំព័ររបស់ធនាគារ
- ឯកសារដែលដកស្រង់ពីរបាយការណ៍របស់និស្សិតបញ្ចប់ការសិក្សាឆ្នាំមុនៗ។

### ៥.២.ការវិភាគទិន្នន័យ

- បន្ទាប់ពីប្រមូលបានព័ត៌មាន និងទិន្នន័យរួមមក ការសិក្សាស្រាវជ្រាវលើប្រធានបទនេះនឹងធ្វើការបកស្រាយនូវទិន្នន័យតាមបែបគុណវិស័យ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈនៃការស្រាវជ្រាវនេះ វានឹងផ្តល់សារៈសំខាន់ជាច្រើនដូចជា:

- ទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀតអំពីដំណើរការនៃការគ្រប់គ្រងរបស់ធនាគារពាណិជ្ជ
- ស្វែងយល់ឲ្យកាន់តែស៊ីជម្រៅអំពីសេវាកម្មរបស់ធនាគារពាណិជ្ជ
- ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវ
- ជាកិច្ចការដ៏សំខាន់សម្រាប់ក្រុមយើងខ្ញុំស្រាវជ្រាវនិងការពារដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ
- អាចជាមតិយោបល់សម្រាប់ធនាគារដែលគ្រប់គ្រងនូវសេវាកម្មទាំងនេះ

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើស្តីពីការគ្រប់គ្រងឥណទាន៖



# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. ស្ថានភាពទូទៅរបស់ធនាគារពាណិជ្ជ

### ១.១.១.ប្រវត្តិរបស់ធនាគារពាណិជ្ជ

[1]ដំបូងធនាគារកើតឡើងពីពាណិជ្ជករនៅសម័យបុរាណដែលបង្កើតឲ្យមានប្រាក់កម្ចីសម្រាប់កសិករ និងពាណិជ្ជករដែលបានដឹកជញ្ជូនទំនិញពីទីក្រុងមួយទៅទីក្រុងមួយ។ កំណត់ហេតុរបស់សកម្មភាពបែបនេះមានមកតាំងពី២០០០ឆ្នាំមុនគ.សនៅក្នុងតំបន់Assyria និងBabylonia។ បន្ទាប់មកនៅប្រទេសក្រិកសម័យបុរាណ និងសម័យរូម៉ាំងឬចក្រភពរ៉ូម អ្នកផ្តល់កម្ចីដែលមានមូលដ្ឋាននៅព្រះវិហារបានបង្កើតប្រាក់កម្ចីហើយក៏បានបង្កើតបន្ថែមនូវការបង្កើតថ្មីសំខាន់ៗចំនួន២គឺ ទទួលការដាក់ប្រាក់ និងការដូររូបិយប័ណ្ណ។ នៅសម័យនោះក៏មានភស្តុតាងស្រដៀងគ្នានៃការអភិវឌ្ឍន៍ឯករាជ្យនៃការខ្ចីប្រាក់នៅសម័យចិនបុរាណ និងសម័យឥណ្ឌាបុរាណ។

នៅក្នុងគំនិតថ្មី ធនាគារត្រូវបានរកឃើញនៅមជ្ឈិមសម័យនិងដើមសម័យនៃការរីកចម្រើនរបស់អ៊ីតាលីនៅក្នុងទីក្រុងអ្នកមាននៅភាគខាងជើងដូចជា Florence, Venice និង Genoa។ គ្រួសាររបស់ Bardi និង Peruzzi បានគ្រប់គ្រងធនាគារនៅក្នុងសតវត្សទី១៤នៃតំបន់ Florence និងបង្កើតសាខានៅក្នុងផ្នែកផ្សេងៗទៀតនៅទ្វីប អឺរ៉ុប។ ប្រហែលជាធនាគារBardici ជាធនាគារដែលល្បីជាងគេរបស់អ៊ីតាលីដែលបានបង្កើតឡើងដោយ Giovanni Madici នៅឆ្នាំ១៣៩៧។

ការរីកចម្រើនរបស់ធនាគារបានរីករាលដាលពេញទ្វីបអឺរ៉ុបហើយមានការបង្កើតឡើងនូវធនាគារថ្មីសំខាន់ៗមួយចំនួនទៀត ត្រូវបានបង្កើតឡើងនៅទីក្រុង Amsterdam នៅសម័យសាធារណរដ្ឋហូឡង់ក្នុងសតវត្សទី១៧។ អំឡុងសតវត្សទី២០ ការអភិវឌ្ឍន៍ក្នុងផ្នែកទូរគមនាគមន៍និងកុំព្យូទ័របានផ្តល់ជាលទ្ធផលយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរនៃការរៀបចំធនាគារហើយក៏មានការធ្វើឱ្យកើនឡើងទាំងទំហំនិងការប្រើប្រាស់តាមតំបន់។ នៅចុងឆ្នាំ២០០០ វិបត្តិហិរញ្ញវត្ថុបានជួបនូវភាពបរាជ័យរបស់ធនាគារមួយចំនួនដែលរួមមានធនាគារធំៗរបស់ពិភពលោក។

ទម្រង់ដំបូងបង្អស់របស់ធនាគារគឺប្រវត្តធនាគារមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិរូបិយវត្ថុ ប៉ុន្តែប្រវត្តិរបស់ធនាគារប្រហែលជាមានមុនការបង្កើតរូបិយវត្ថុ។ការផ្ញើប្រាក់ដំបូងរួមមានការផ្ញើរជាគ្រាប់

[1] ងួន ហេង និងសាង សុមុន្នី, រូបិយវត្ថុ និងធនាគារ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩, ទំព័រទី៥៨-៦១

ធញ្ញជាតិហើយបន្ទាប់មកមានជាទំនិញដែលរួមមានសត្វពាហនៈ សម្ភារៈកសិកម្ម ហើយរួមទាំងវត្ថុមានតម្លៃដូចជាមាសជាដើម។ ព្រះវិហារនិងវាំងគឺជាកន្លែងដែលសុវត្ថិភាពបំផុតសម្រាប់រក្សាទុកមាសដែលពួកសាងសង់ឡើងយ៉ាងរឹងមាំ។ ដោយសារតែព្រះវិហារជាកន្លែងសាសនាវាបានបង្ហាញភាពភ័យខ្លាចដល់ជនខិលខូច។ Mesopotamia កំណត់ហេតុអំពីប្រាក់កម្ចីមានតាំងពីសតវត្សទី២មុនគ.ស ក្នុងតំបន់ Babylon ដែលបានបង្កើតឡើងដោយអាចារ្យឬព្រះសង្ឃទៅឲ្យពួកពាណិជ្ជករ។ ត្រឹមពេលនៃ Hammurabi's Code រហូតដល់ Ca ក្នុងឆ្នាំ១៧៦០ មុនគ.ស ធនាគារមានលក្ខណៈគ្រប់គ្រាន់ដែលអាចអភិវឌ្ឍទៅដល់ការកំណត់ច្បាប់គ្រប់គ្រងការរៀបចំធនាគារ។

ក្នុងប្រទេសអេហ្ស៊ីប កាលពីមុនគ្រាប់ធញ្ញជាតិត្រូវបានប្រើប្រាស់ក្នុងទម្រង់ជារូបិយវត្ថុរួមទាំងលោហធាតុមានតំលៃហើយនិងជង្រុករបស់រដ្ឋដែលមានមុខងារជាធនាគារ។ ពេលដែលប្រទេសអេហ្ស៊ីបធ្លាក់ចូលការគ្រប់គ្រងរបស់ក្រិច(៣៣២-៣០០មុនគ.ស) រដ្ឋាភិបាលបានប្រែក្លាយឲ្យទៅជាប្រព័ន្ធធនាគារធញ្ញជាតិ។ ប្រព័ន្ធធនាគារនេះមានមុខងារជាប្រព័ន្ធឥណទានពាណិជ្ជកម្មដែលក្នុងនោះរាល់ការចំណាយត្រូវបានផ្ទេរពីគណនីមួយទៅគណនីមួយទៀតដោយគ្មានការបញ្ជូនប្រាក់។ នៅចុងសតវត្សទី១៣មុនគ.សកោះAegean ដែលជាកោះគ្មានជីវជាតិនៅតំបន់នៃ Delos ត្រូវបានគេស្គាល់ដោយសារកំពង់ផែនិងប្រាសាទល្បីរបស់ Apollo បានក្លាយជាមជ្ឈមណ្ឌលធនាគារដ៏សំខាន់។ ក្នុងប្រទេសអេហ្ស៊ីបប្រតិបត្តិការសាច់ប្រាក់ត្រូវបានជំនួសដោយវិក័យប័ត្រឥណទានហើយការចំណាយត្រូវបានធ្វើឡើងដោយផ្អែកទៅតាមការបញ្ជាជាមួយនឹងគណនីអតិថិជននីមួយៗ។

ក្នុងប្រទេសឥណ្ឌាសម័យបុរាណអំឡុងរាជវង្ស Maurya (៣២១-១៨៥មុនគ.ស) ការបង្គាប់មួយត្រូវបានគេហៅ Adesha ត្រូវបានគេប្រើប្រាស់ដែលជាបញ្ជារបស់ធនាគារិកឲ្យគាត់បង់ក្រដាសប្រាក់ឲ្យទៅតតិយជនដែលឆ្លើយតបទៅនឹងនិយមន័យវិក័យប័ត្របង់ប្រាក់ដូចមានប្រើប្រាស់សព្វថ្ងៃនេះ។

ក្នុងប្រទេសចិនបុរាណចាប់ពីរាជវង្ស Quin (២២១-២០៦មុនគ.ស) រូបិយប័ណ្ណចិនបានរីកចម្រើនដោយសារការបង្ហាញកាក់ស្តង់ដារដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មក្នុងប្រទេសហើយនាំឲ្យមានការអភិវឌ្ឍទៅជាក្រដាសឥណទាន។ ក្រដាសនេះបានចេញដោយពាណិជ្ជករដែលរកស៊ីតាមមធ្យោបាយជាច្រើនដែលសព្វថ្ងៃនេះយល់ថាដូចជាធនាគារ។

នៅប្រទេសក្រិកសម័យបុរាណមានសេវាកម្មបញ្ញើទ្រព្យដែលមានតម្លៃទុកក្នុងឃ្លាំងដែលមានសុវត្ថិភាពសម័យនោះក្រិចក៏បានបង្កើតប្រាក់កាក់និងប្រព័ន្ធឥណទានផងដែរ។ ចំពោះចក្រភពរ៉ូមវិញមានការរីកចម្រើនវិស័យធនាគារយ៉ាងខ្លាំងហើយធនាគារនោះមានសេវាកម្មបញ្ញើរ កម្ចី និងទិញវត្ថុបញ្ចាំ។ ប្រព័ន្ធធនាគារនៅអឺរ៉ុបក៏មានការរីកចម្រើនយ៉ាងខ្លាំងដែរ ប៉ុន្តែបន្ទាប់ពីការដួលរលំនៃចក្រភពរ៉ូមប្រព័ន្ធធនាគារនៅអឺរ៉ុបមានការធ្លាក់ចុះ

វិញ។

នៅសតវត្សទី១៣ មានការរីកចម្រើនខាងវិស័យពាណិជ្ជកម្មក្នុងប្រទេសអ៊ីតាលីដោយបានពង្រីកប្រព័ន្ធធនាគារឡើយវិញ។ អ្នកប្តូរប្រាក់បានកែប្រែប្រព័ន្ធប្តូរប្រាក់ឲ្យមានទាំងអត្រាប្តូរប្រាក់ជាតិនិងអន្តរជាតិ។ បន្ទាប់មកទៀតពាណិជ្ជករមានតម្រូវការផ្សេងៗទៀតដូចជាសេវាកម្មកម្ចីសម្រួលរបស់ពាណិជ្ជករជាដើមបន្ទាប់មកធនាគារក៏បានពង្រីកសេវាកម្មរបស់ខ្លួនជាបន្តបន្ទាប់។

ធនាគារដំបូងបង្អស់ដែលបានផ្តល់សេវាកម្មដូចសព្វថ្ងៃនេះគឺធនាគារក្នុងតំបន់ Babylon នៃប្រទេស Mesopotamia ធនាគារនេះកើតឡើងនៅឆ្នាំ១៨០១ ដែលផ្តល់សេវាកម្មបញ្ញើ ប្តូរប្រាក់ និងផ្តល់កម្ចី ហើយធនាគារនេះជាធនាគារដែលបង្កើតមូលប្បទានប័ត្រមុនគេ។ បន្ទាប់មកមានធនាគារបីទៀតបានកើតឡើងជាបន្តបន្ទាប់គឺធនាគារ The Bank of Venice (1857) The Bank of Amsterdam (1609) និ The Bank of Hamburg (1619)។

ធនាគារប្រទេសបារាំងបង្កើតឡើងដោយណាប៉ូឡេអុងក្នុងឆ្នាំ១៨០០។ នៅពាក់កណ្តាលសតវត្សទី១៨ ធនាគារនេះបានក្លាយជាស្ថាប័នហិរញ្ញវត្ថុដែលមានឥទ្ធិពលបំផុត។

នៅអាឡឺម៉ង់ប្រព័ន្ធធនាគារមានការអភិវឌ្ឍជាលំដាប់ហើយនៅពាក់កណ្តាលសតវត្សទី១៩ មានការបង្កើតភាគហ៊ុនមួយចំនួនដ៏រឹងមាំទៀតផង។

ប្រព័ន្ធធនាគារនៅប្រទេសអង់គ្លេសបានកើតឡើងដោយជាងមាសក្នុងសតវត្សទី១៦។ អ្នកទាំងនោះបានផ្តល់កម្ចី និងទទួលរក្សាទុកវត្ថុមានតម្លៃផ្សេងៗដោយគិតជាថ្លៃសេវា។ នៅសតវត្សទី១៧ ជាងមាសដែលជាម្ចាស់ធនាគារទាំងនោះបានបង្កើតការបង្វិលសាច់ប្រាក់ដោយយកប្រាក់ដែលអតិថិជនផ្ញើរទៅផ្តល់ជាកម្ចី។ អតិថិជនបានយកមាសទៅផ្ញើរនឹងជាងមាសដោយទទួលមកវិញនូវវិក័យប័ត្រដែលបញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួនដោយវិក័យប័ត្រទាំងនោះអាចប្រើជាលុយបានព្រោះវាបានបញ្ជាក់ពីចំនួនមាសដែលពួកគេមាន។ ប្រតិបត្តិការនេះអាចដំណើរការបានយូរអង្វែងប្រសិនបើអតិថិជនទាំងនោះមិនមកដកភ្លាមៗនោះទេ ដោយការធ្វើបែបនេះធ្វើឲ្យចំនួនវិក័យប័ត្រកើនឡើងច្រើនជាងចំនួនមាសដែលមានព្រោះតែព្រឹត្តិការណ៍បែបនេះហើយបានធ្វើឲ្យធនាគារិកចាប់ផ្តើមបង្កើតក្រដាសប្រាក់។

នៅសហរដ្ឋអាមេរិច ធនាគារដំបូងកើតឡើងនៅសតវត្សទី១៨ ដើម្បីផ្តល់រូបិយវត្ថុដល់ពួកអាណានិគមដែលត្រូវការប្តូរប្រាក់។ ដំបូងឡើយធនាគារផ្តល់កម្ចីនិងចេញវិក័យប័ត្រសម្រាប់ការដាក់ប្រាក់នៅធនាគារតែប៉ុណ្ណោះ។ គណនីមូលបត្រកើតឡើងនៅពាក់កណ្តាលសតវត្សទី១៩ បន្ទាប់មកទៀតសេវាកម្មថ្មីៗរបស់ធនាគារបានកើតឡើងជាបន្តបន្ទាប់តាមរយៈប្រព័ន្ធធនាគាររបស់រដ្ឋ។

ដោយសារការរីកចម្រើនខាងសេដ្ឋកិច្ចនិងបច្ចេកទេសបានធ្វើឲ្យប្រតិបត្តិការរបស់ធនាគារកាន់តែរីក

ចម្រើនដោយផ្តល់កម្ចីរយៈពេលវែង ផ្តល់កម្ចីរយៈពេលមធ្យមសម្រាប់អតិថិជននិងអ្នកវិនិយោគទុន ពាណិជ្ជករ ហើយបង្កើតឡើងនូវសេវាកម្មប្រាក់បញ្ញើគ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជនទាំងឡាយ។

**១.១.២.និយមន័យ**

ធនាគារពាណិជ្ជគឺជានីតិបុគ្គលដែលមានសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតីដែលអនុវត្តនូវសកម្មភាពដូចជាៈ ទទួលប្រាក់បញ្ញើរពីសាធារណជន ផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូរទាត់។[2]

ធនាគារពាណិជ្ជគឺជាប្រភេទមួយនៃអន្តរការីហិរញ្ញវត្ថុនិងប្រភេទមួយរបស់ធនាគារដែលផ្តល់គណនីមូលប្បទានប័ត្រ គណនីសន្សំ គណនីទីផ្សាររូបិយវត្ថុ និងទទួលគណនីមានកាលកំណត់ដល់សាធារណជន។

ធនាគារពាណិជ្ជគឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្គត់ផ្គង់នូវសេវាហិរញ្ញវត្ថុដូចជា ការផ្តល់ឥណទាន ការទទួលប្រាក់បញ្ញើ បម្រើសេវាទូទាត់ និងសេវាកម្មជាច្រើនទៀត។

**១.១.៣.តួនាទីរបស់ធនាគារពាណិជ្ជ**

ធនាគារពាណិជ្ជបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចនិងក្នុងផ្នែកផ្សេងៗទៀត។ ធនាគារពាណិជ្ជផ្តល់ជូនអតិថិជននូវសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ។ ក្នុងនោះដែរតួនាទីសំខាន់ៗរបស់ធនាគារពាណិជ្ជមានដូចជាៈ

**១.១.៣.១.តួនាទីអន្តរការី**

ធនាគារ មាននាទីបង្វែរការសន្សំជាសាច់ប្រាក់ពីគ្រួសារទៅជាឥណទានសម្រាប់សហគ្រាសពាណិជ្ជកម្មនិងសហគ្រាសផ្សេងទៀតដើម្បីវិនិយោគក្នុងការសាងសង់ សម្ភារៈបរិក្ខារ ឧបករណ៍ប្រើប្រាស់ និងទំនិញផ្សេងៗ។

**១.១.៣.២.តួនាទីទូទាត់**

ធនាគារ មាននាទីជាការអនុវត្តនូវការទូទាត់ផ្សេងៗ សម្រាប់ទំនិញនិងសេវាកម្មក្នុងនាមអតិថិជនរបស់ពួកគេដូចជាការចេញនិងទូទាត់ជម្រះមូលប្បទានប័ត្រ ផ្ទេរសាច់ប្រាក់និងទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងការដកប្រាក់តាមប្រព័ន្ធម៉ាស៊ីនATM។

**១.១.៣.៣.តួនាទីជាអ្នកធានា**

ធនាគារ មាននាទីឈរពីក្រោយអតិថិជនរបស់ពួកគេដើម្បីធ្វើការទូទាត់ឬសងនូវបំណុលរបស់អតិថិជន នៅពេលដែលអតិថិជនទាំងនោះមិនអាចសងទៅម្ចាស់បំណុលរបស់ពួកគេ។

**១.១.៣.៤.តួនាទីជាភ្នាក់ងារ**

---

[2] ងួន ហេង និងសាង សុមុន្នី, *"រូបិយវត្ថុ និងធនាគារ,"* (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩) ទំព័រទី៥៨។

ធនាគារ មាននាទីជាអ្នកតំណាងឲ្យអតិថិជនដើម្បីចាប់ចែងនិងការពារនូវទ្រព្យសម្បត្តិរបស់ពួកគេឬចេញ និងលោះឬទទួលទូទាត់លក់ចេញនិងទិញចូលនូវប័ណ្ណភាគហ៊ុន។

**១.១.៣.៥.តួនាទីគ្រប់គ្រងហានិភ័យ**

ធនាគារ មាននាទីជួយទៅដល់អតិថិជននៅក្នុងការរៀបចំនូវការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុសម្រាប់ការពារនិងបញ្ចៀសហានិភ័យនៃការបាត់បង់ទ្រព្យសម្បត្តិនិងជីវិតមនុស្ស។

**១.១.៣.៦.តួនាទីជាទីប្រឹក្សាលើការសន្សំ**

ធនាគារ មាននាទីជួយដល់អតិថិជនលើការផ្តល់ការប្រឹក្សាយោបល់សម្រាប់គោលដៅរយៈពេលវែងក្នុងការធ្វើឱ្យមានជីវិតល្អប្រសើរដូចជាគម្រោងសាងសង់ឬគម្រោងអាជីវកម្មផ្សេងៗ ដើម្បីជៀសវាងការទុកប្រាក់សន្សំមិនចរាចរនៅលើទីផ្សារ។

**១.១.៣.៧.តួនាទីជាអ្នកថែរក្សាទ្រព្យសម្បត្តិមានតម្លៃ**

ធនាគារ មាននាទីទុកដាក់វត្ថុមានតម្លៃរបស់អតិថិជននិងវាយតម្លៃប្រកបដោយសុក្រិតភាពនូវតម្លៃរបស់ទ្រព្យសកម្មឬទ្រព្យសម្បត្តិដែលធ្វើប្រតិបត្តិការនៅលើទីផ្សារ។

**១.១.៣.៨.តួនាទីជាអ្នកអនុវត្តគោលនយោបាយ**

ធ្វើប្រតិបត្តិការស្របតាមគោលនយោបាយក្នុងគោលបំណងធ្វើឱ្យមានកំណើនសេដ្ឋកិច្ចនិងឈានទៅដល់គោលដៅដែលសង្គមចង់បាន។

## ១.២.សេវាកម្មទូទៅរបស់ធនាគារពាណិជ្ជ

### ១.២.១.សេវាឥណទាន

#### ១.២.១.១.និយមន័យ

[3]ឥណទាន គឺជាការផ្តល់ឬសន្យាផ្តល់ឲ្យនូវមូលនិធិសម្រាប់ទុនអាជីវកម្មតែត្រូវសងមកវិញដោយមានការប្រាក់ឬជាការធានាតាមហត្ថលេខាដើម្បីសងជួយកូនបំណុលចំពោះម្ចាស់បំណុល។

[4]ឥណទាន គឺជាការផ្ទេរសិទ្ធិឬសិទ្ធិប្រើប្រាស់ជាបណ្តោះអាសន្នទៅឲ្យអ្នកខ្ចីនូវបរិមាណតម្លៃមួយអាចជាវត្ថុឬរូបិយវត្ថុ(លុយ)ជាមួយនឹងការសន្យាសងត្រឡប់វិញដល់ម្ចាស់ទាំងដើមនិងការប្រាក់។

#### ១.២.១.២.ប្រភេទឥណទាន

**ក.ឥណទានឯកជន**

[3] ងួន ហេង និងសាង សុមុន្នី, *"រូបិយវត្ថុ និងធនាគារ,"* (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩) ទំព័រទី៧៨។

[4]ឈាង ហ៊ុយ, *"ការគ្រប់គ្រងឥណទាន"* (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩) ទំព័រទី៥។

ឥណទានឯកជនគឺជាឥណទានដែលត្រូវបានប្រើប្រាស់ដោយបុគ្គល គ្រួសារ រួមទាំងសហគ្រាសជាច្រើនដែលនាំឲ្យមានការដោះដូរនូវទំនិញឬសេវាកម្មនិងមូលនិធិនៅក្នុងផ្នែកឯកជន។

ឥណទានឯកជនរួមមាន៖

➢ ឥណទានសម្រាប់អ្នកប្រើប្រាស់

ឥណទានសម្រាប់អ្នកប្រើប្រាស់ គឺជាការប្រើប្រាស់ឥណទានជាមធ្យោបាយនៃការដោះដូរសម្រាប់ការទិញទំនិញនិងសេវាកម្មដោយមិនមានដែនកំណត់របស់អ្នកប្រើប្រាស់។ ឥណទានសម្រាប់អ្នកប្រើប្រាស់ចែកចេញជា៣គឺ៖

- ឥណទានរាយ គឺជាឥណទានដែលអ្នកប្រើប្រាស់ទិញទំនិញសម្រេចនិងសេវាកម្មដោយផ្ទាល់ពីអ្នកលក់ដោយប្រើជា ឥណទានបង្វិល កិច្ចសន្យាបង់រំលោះ និងឥណទានសេវាកម្ម
  - ⇨ ឥណទានបង្វិល៖ជាកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ទំនិញដោយប្រើប្រាស់ឥណទានរហូតដល់ចំនួនអតិបរមាកំណត់មួយ
  - ⇨ ឥណទានសងរំលោះ៖ជាការទិញដែលមានទ្រង់ទ្រាយធំហើយដែលទិញជាសេរីថេរសំណាងទៀងទាត់រយៈពេលវែងកំណត់តាមពេលវេលា។កិច្ចសន្យានេះនឹងធ្វើឡើងនៅពេលទិញទំនិញម្តងៗ
  - ⇨ ឥណទានសេវា៖ជាឥណទានដែលកើតឡើងពីអ្នកផ្គត់ផ្គង់សេវាយល់ព្រមផ្តល់ហើយរងចាំសំណាងពីអតិថិជន។គ្មានកិច្ចសន្យាផ្លូវការនិងសំណាងត្រូវទូទាត់តាមវិក័យបត្រដូចជាវេជ្ជបណ្ឌិត ទន្តពេទ្យ។
- ឥណទានសាច់ប្រាក់ ជាឥណទានដែលអ្នកខ្ចីទទួលមូលនិធិពីអ្នកផ្គត់ផ្គង់កម្ចីដោយដោះដូជាមួយនឹងកិច្ចព្រមព្រៀងសងត្រឡប់វិញរួមជាមួយការប្រាក់ឬបន្ទុកហិរញ្ញវត្ថុ។ អតិថិជនច្រើនប្រើមូលនិធិនេះក្នុងគោលបំណងដូចជា វិស្សមកាល អាពាហ៍ពិពាហ៍ ឬកិច្ចការបន្ទាន់ដែលជាតម្រូវការចាំបាច់ផ្សេងៗ។ វិធីទូទាត់មានដូចជាការសងរំលោះ ឬសងតែម្តង។
  - ⇨ ការសងរំលោះ ជាកម្ចីរៀបជាសេរីថេរសម្រាប់សំណាងទៀងទាត់មានដូចជា Student loan Car loan។
  - ⇨ ឥណទាទូទាត់តែម្តង ជាទូទៅកម្ចីមានរយៈពេលខ្លីដែលអ្នកខ្ចីទទួលបានប្រាក់កក់មុនសម្រាប់រយៈពេល១ឆ្នាំ ឬតិចជាងនេះជាមួយនឹងកិច្ចសន្យាសងវិញតែម្តងទាំងការទាំងដើមនៅពេលកំណត់ជាក់លាក់។

- ឥណទានអចលនទ្រព្យ គឺជាឥណទានប្រភេទទី៣នៃឥណទានសម្រាប់អ្នកប្រើប្រាស់ក្នុងការទិញអចលនទ្រព្យឬបំណងផ្សេងៗដែលក្នុងនោះមូលនិធិដែលផ្តល់ឱ្យអ្នកខ្ចីត្រូវធានាដោយអចលនទ្រព្យដាក់បញ្ចាំសម្រាប់កម្ចី។

➢ ឥណទានអាជីវកម្ម

ឥណទានអាជីវកម្ម គឺជាឥណទានដែលចំណាស់ជាងគេ។ អ្នកផ្គត់ផ្គង់ អ្នកផលិត អ្នកលក់ និងក្រុមហ៊ុនត្រូវការវត្ថុធាតុដើម និងទំនិញសារពើភ័ណ្ឌសម្រាប់នាំចេញទៅសហគ្រាសរបស់ពួកគេ។ ប្រសិនបើពេលវេលាត្រូវបានពន្យារពេលនៅចន្លោះពេលផលិតនិងការទទួលយកនូវមូលនិធិត្រឡប់មកវិញពីការលក់ ដូច្នេះជារឿយៗឥណទានត្រូវបានកើនឡើង។

- ឥណទានសម្រាប់លក់ ជាឥណទានសម្រាប់ទិញទំនិញ វត្ថុធាតុដើម និងសារពើភ័ណ្ឌសម្រាប់លក់បន្ត។ ជាទូទៅអតិថិជនទទួលបានទំនិញមុនហើយយល់ព្រមទូទាត់តាមលក្ខខណ្ឌលក់របស់អ្នកលក់ និងអនុញ្ញាតឱ្យអតិថិជនទូទាត់តាមពេលវេលាកំណត់។
- មូលនិធិហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការ ជាតម្រូវការចាំបាច់សម្រាប់ការចាប់ផ្តើមថែរក្សានិងប្រតិបត្តិការអាជីវកម្ម។

**ខ.ឥណទានសាធារណៈ**

ឥណទានសាធារណៈជាប្រភេទកម្ចីកម្រិតរដ្ឋាភិបាលសម្រាប់ធ្វើហិរញ្ញប្បទានទិញទំនិញ សេវាកម្ម និងកម្មវិធីសុខុមាលភាព ការសង្គ្រោះដល់ប្រជាពលរដ្ឋរបស់ពួកគេ ក៏ដូចជាប្រជាពលរដ្ឋនៅទូទាំងប្រទេសផងដែរ។

### ១.២.២.សេវាទទួលប្រាក់បញ្ញើ

#### ១.២.២.១.និយមន័យ

[5]បញ្ញើ ជាកិច្ចសន្យាដែលបុគ្គលម្នាក់ហៅថា"អ្នកផ្ញើរ" យកចលនវត្ថុទៅដាក់ផ្ញើរនឹងបុគ្គលម្នាក់ទៀតហៅថា"អ្នកទទួលបញ្ញើ" ដែលយល់ព្រមទទួលទុកចលនវត្ថុនោះហើយសន្យាថានឹងប្រគល់ឲ្យអ្នកផ្ញើវិញនៅពេលអ្នកផ្ញើរស្នើសុំ ដែលចលនវត្ថុទាំងនោះរួមមាន ប្រាក់ មូលបត្រឬទ្រព្យដទៃទៀតដែលមានតម្លៃផ្សេងៗ។

#### ១.២.២.២.ប្រភេទនៃប្រាក់បញ្ញើ

**ក.គណនីចរន្ត** គឺជាសេវាមួយក្នុងចំណោមសេវាសំខាន់ៗ ទាំងឡាយនៃឧស្សាហកម្មធនាគារព្រោះវាបង្កើនប្រសិទ្ធភាពនៃដំណើរការទូទាត់ដែលធ្វើឲ្យប្រតិបត្តិការជំនួញមានលក្ខណៈងាយស្រួលរហ័សនិងមានសុវត្ថិភាពច្រើន។

[5] ងួន ហេង និងសាង សុមុន្នី, *"រូបិយវត្ថុ និងធនាគារ,"* សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩, ទំព័រទី ៧១។

**ខ.គណនីបញ្ញើសន្សំ** ជាប្រាក់បញ្ញើដែលធនាគារផ្តល់ការប្រាក់ទាបបំផុតហើយអតិថិជនអាចដក ឬ ដាក់ប្រាក់បញ្ញើពេលណាក៏បាន

**គ.គណនីបញ្ញើសន្សំជូនដំណឹង** ជាគណនីបញ្ញើសន្សំមួយប្រភេទដែលធនាគារផ្តល់ការប្រាក់ខ្ពស់ជាងគណនីបញ្ញើសន្សំធម្មតា ដោយគណនីនេះជាប្រភេទគណនីដែលអាចឲ្យអតិថិជនដកប្រាក់បានប៉ុន្តែអតិថិជនត្រូវជូនដំណឹងជាមុន។

**ឃ.គណនីបញ្ញើតាមតម្រូវការ** ជាគណនីបញ្ញើសន្សំមួយប្រភេទដែលមានលក្ខណៈដូចគ្នានឹងគណនីបញ្ញើសន្សំធម្មតាដែរ ប៉ុន្តែគណនីនេះមិនប្រើសៀវភៅគណនីទេ ដូចនេះអតិថិជនចាំបាច់ត្រូវបោះពុម្ព bank statement ជូនអតិថិជនរៀងរាល់ខែ។

**ង.គណនីបញ្ញើមានកាលកំណត់** ជាគណនីដែលធនាគារពាណិជ្ជផ្តល់ជូនអតិថិជនជាលក្ខណៈពិសេសក្នុងការវិនិយោគសាច់ប្រាក់ដែលមានរយៈពេលជាក់លាក់មួយទើបអាចដកសាច់ប្រាក់នោះបាន ដោយគណនីប្រភេទនេះធនាគារពាណិជ្ជផ្តល់ការប្រាក់ខ្ពស់ជាងគណនីបញ្ញើសន្សំធម្មតា។

**ច.គណនី Corporate Deposit** ជាផលិតផលប្រាក់បញ្ញើសន្សំដែលធនាគារផ្តល់ជូនអតិថិជនជាក្រុមហ៊ុនដែលមានសក្តានុពលធំៗ ហើយមានតម្រូវការផ្ញើសាច់ប្រាក់ក្នុងរយៈពេលកំណត់។

**ឆ.គណនី Trust** ជាគណនីមួយប្រភេទដែលធនាគារទទួលខុសត្រូវក្នុងការថែរក្សាគ្រប់គ្រង និងចាត់ចែងប្រាក់ឬទ្រព្យសម្បត្តិរបស់អតិថិជនទៅតាមកិច្ចសន្យាឬកិច្ចព្រមព្រៀងរវាងធនាគារនិងអតិថិជន។

**ជ.គណនីមូលនិធិសិក្សាអប់រំ** ជាសេវាបញ្ញើសន្សំមួយប្រភេទដែលធនាគារពាណិជ្ជទទួលខុសត្រូវថែរក្សាគ្រប់គ្រងនិងចាត់ចែងសាច់ប្រាក់ដែលអតិថិជនដាក់ប្រាក់សន្សំក្នុងគោលបំណងសម្រាប់ទូទាត់រាល់ការចំណាយផ្សេងៗ ដែលពាក់ព័ន្ធនឹងការសិក្សាអប់រំ ដូចជា បង់ថ្លៃសាលារៀន ថ្លៃទិញសម្ភារៈសិក្សាជាដើម។

**ឈ.គណនី EURO Account** គឺជាគណនីចរន្តប្រាក់អឺរ៉ូ អតិថិជនបើកគណនីនេះធនាគារអនុញ្ញាតធ្វើប្រតិបត្តិការដក-ដាក់សាច់ប្រាក់ ឬមូលប្បទានប័ត្រជាប្រាក់អឺរ៉ូ ប្រាក់ដុល្លារឬបាតថៃតាមសេចក្តីត្រូវការដោយផ្អែកលើអត្រាប្តូរប្រាក់របស់ធនាគារពាណិជ្ជនៅពេលធ្វើប្រតិបត្តិការដកឬដាក់ប្រាក់។

**ញ.សេវាបញ្ញើឯកសារមានតម្លៃ** ជាប្រភេទបញ្ញើដែលធនាគារពាណិជ្ជទទួលថែរក្សានិងគ្រប់គ្រងឯកសារមានតម្លៃផ្សេងៗជូនអតិថិជន។

### ១.២.៣.សេវាផ្ទេរប្រាក់

#### ១.២.៣.១.និយមន័យ

សេវាផ្ទេរប្រាក់ គឺជាសេវាមួយប្រភេទដែលធនាគារអនុញ្ញាតឲ្យអតិថិជនអាចធ្វើការផ្ទេរប្រាក់ ឬទទួលប្រាក់ទាំងក្នុងប្រទេស និងក្រៅប្រទេស។

**១.២.៣.២.ប្រភេទសេវាផ្ទេរប្រាក់**

**ក.សេវាផ្ទេរប្រាក់ក្នុងស្រុក** គឺជាប្រតិបត្តិការនៃការផ្ទេរប្រាក់ពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងប្រទេស។

**ខ.សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមWESTERN UNION** ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការផ្ញើរ និងទទួលប្រាក់ពីក្រៅប្រទេសបានរហ័ស និងងាយស្រួល។

**គ.សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមប្រព័ន្ធSWIFT** គឺជាការផ្ទេរប្រាក់រវាងធនាគារពាណិជ្ជទៅធនាគារផ្សេងនៅក្រៅប្រទេស ដោយការផ្ទេរឬការទទួលប្រាកើតាមរយៈធនាគារដែលជាភ្នាក់ងារ។

**១.២.៤.សេវាផ្សេងទៀត**

**ក.សេវាប្តូរប្រាក់** ធនាគារធ្វើការប្តូររូបិយប័ណ្ណជាតិទៅជារូបិយប័ណ្ណបរទេស ឬការប្តូររូបិយប័ណ្ណបរទេសទៅជារូបិយប័ណ្ណជាតិ ដោយរូបិយប័ណ្ណក្នុងការប្តូរនេះមានដូចជា ប្រាក់រៀល ប្រាក់ដុល្លារ ប្រាក់យ័ន ប្រាក់បាត ប្រាក់ដុង ជាដើម។

**ខ.សេវាធានារ៉ាប់រងអាយុជីវិត** គឺជាសេវាមួយប្រភេទដែលអាចធ្វើឲ្យអតិថិជនមាននិរន្តភាពនៃប្រាក់ចំណូលដើម្បីឲ្យជីវភាពរស់នៅរបស់គ្រួសារអតិថិជនមានស្ថេរភាពក្នុងករណីមានហេតុការណ៍ណាមួយកើតឡើងជាយថាហេតុ។

**គ.សេវាហិរញ្ញប្បទានពាណិជ្ជកម្ម** គឺជាសកម្មភាពមួយដែលធនាគារធ្វិឲ្យមានសុក្រិតភាពពាណិជ្ជកម្មរវាងអ្នកលក់ និងអ្នកទិញតាមរយៈធនាគារឬអន្តរការីធនាគារក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។

**១.៣.ដំណើរការនៃការគ្រប់គ្រងឥណទាន**

**១.៣.១.ការផ្សព្វផ្សាយ**

ការជូនព័ត៌មានដល់អតិថិជនឲ្យដឹងអំពីផលិតផលនិងសេវាកម្មគឺជាការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយដោយផ្ទាល់តាមទូរទស្សន៍ វិទ្យុ អ៊ីនធើណេត និងឧបករណ៍ផ្សេងៗទៀត។ ការផ្តល់ពត៌មានដល់អតិថិជនក្នុងគោលបំណងចង់ឲ្យអតិថិជនប្រើប្រាស់នូវផលិតផលក៏ដូចជាសេវាកម្មរបស់ធនាគាររួមទាំងការណែនាំជាចំណេះដឹងដល់ការប្រើប្រាស់នូវផលិតផលនិងសេវាកម្ម។

**១.៣.២.ការជ្រើសរើសសំណើរសុំ**

ការជ្រើសរើសពាក្យស្នើសុំពណ៌នាអំពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកធ្វើការដោយមានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យឲ្យឃើញថាអ្នកស្នើសុំឥណទានមានលក្ខខណ្ឌមូលដ្ឋានត្រឹមត្រូវសម្រាប់បើកគណនីឥណទាន។ បច្ចុប្បន្ន អ្នកផ្តល់ឥណទានជាច្រើនប្រើប្រាស់នូវប្រព័ន្ធដាក់ពិន្ទុឥណទានដែលជាទម្រង់ស្ថិតិមូលដ្ឋាន ឬកម្មវិធីដោយកំព្យូទ័រដែលកំណត់ពិន្ទុទៅតាមរបាយការណ៍ដែលមាននៅក្នុងពាក្យស្នើសុំ របាយការណ៍ហិរញ្ញវត្ថុ

ឬរបាយការណ៍នៃការិយាល័យឥណទាន។ ក្នុងអាជីវកម្មឥណទាន ពិន្ទុផ្អែកលើអនុបាតហិរញ្ញវត្ថុដែលគណនាទ្រព្យសកម្ម បំណុល និងចំណូលរបស់អ្នកស្នើសុំឥណទាន។ អ្នកចេញប័ណ្ណឥណទានរាយមួយចំនួន ប្រើប្រព័ន្ធដាក់ពិន្ទុឥណទានដើម្បីធ្វើការសម្រេចចិត្តនៅក្នុងការផ្តល់ប័ណ្ណឥណទាន និងកំណត់ទំហំឥណទានទៅលើគណនីនីមួយៗ។

### ១.៣.៣.ការស៊ើបអង្កេត

ការស៊ើបអង្កេតឥណទានពាក់ព័ន្ធនឹងជំហានដើម្បីត្រួតពិនិត្យព័ត៌មានលើពាក្យស្នើសុំឥណទាន និងកំណត់ថាអតិថិជនទទួលបានហិរញ្ញវត្ថុដោយរបៀបណា។ ការស៊ើបអង្កេតឥណទានត្រូវធ្វើឡើងដើម្បីធ្វើការសម្រេចចិត្តត្រឹមត្រូវ។ ជាទូទៅដើម្បីជាមូលដ្ឋានក្នុងការស៊ើបអង្កេត ការប្រើប្រាស់ 5Cs ត្រូវបានគេជ្រើសរើសជាឧបករណ៍វិភាគឥណទាន។ 5Cs គឺជាការកាត់យកអក្សរខាងមុខរបស់ភាសាអង់គ្លេសនៃពាក្យ Character, Capacity, Capital, Collateral និង Condition។ អ្នកគ្រប់គ្រងឥណទានជាច្រើនបានជ្រើសរើសយកពាក្យទាំងអស់នេះសម្រាប់ធ្វើការស៊ើបអង្កេតឥណទានព្រោះដើម្បីវាយតម្លៃពីគុណសម្បត្តិឥណទានមុនពេលសម្រេចចិត្ត។

**ចរិកលក្ខណៈ(Character)៖** គឺជាអាកប្បកិរិយា ឬការសំដែងចេញរបស់អតិថិជនខណៈពេលដែលគាត់ និយាយស្តី ឆ្លើយសំណួរជាដើម។ ជាពិសេសគឺ សីលធម៌របស់គាត់ក្នុងការធ្វើអាជីវកម្មឬឥរិយាបថ ក្នុងការរស់នៅប្រចាំថ្ងៃ។ ជាទូទៅ ចរិកលក្ខណៈរបស់មនុស្សម្នាក់ៗតែងតែមានលក្ខណៈខុសប្លែកពីគ្នាដែលធ្វើអោយមានការពិបាកក្នុងការវាយតម្លៃពីចរិកលក្ខណៈរបស់ពួកគេណាស់ដូចនេះភ្នាក់ងារឥណទានត្រូវដឹងអោយបានច្បាស់លាស់ពី គោលបំណងនៃការសុំខ្ចីឥណទានរបស់អតិថិជនហើយត្រូវស្វែងរកព័ត៌មានបន្ថែមពីសំណាក់មេឃុំ មេភូមិ មន្ត្រីមានសមត្ថកិច្ចក្នុងតំបន់ ឬ អ្នកជិតខាងដើម្បីបានព័ត៌មានពីអតិថិជនកាន់តែច្បាស់ថែមទៀត។ បន្ទាប់មក ភ្នាក់ងារឥណទាន ត្រូវកំណត់ឲ្យបានច្បាស់ថាអតិថិជន ពិតជាមានភាពស្មោះត្រង់ មានទំនួលខុសត្រូវខ្ពស់ និង មាន ឆន្ទៈក្នុងការសងត្រលប់មកវិញឬទេ? ហើយកត្តាទាំងនេះ ភ្នាក់ងារឥណទានត្រូវតែយកចិត្ត ទុកដាក់ និង មានការពិចារណាអោយបានច្បាស់លាស់បំផុត៕

**សមត្ថភាព(Capacity)៖** គឺសំដៅទៅលើលទ្ធភាពសងត្រលប់របស់អតិថិជននៅពេលដល់ថ្ងៃកំណត់សង។ ការវិភាគទៅលើលទ្ធភាពសងបំណុលត្រលប់ជាទូទៅគេវិភាគទៅលើមុខរបរ ប្រាក់ ចំណូល កម្រិតការចំណាយ តើវាមានភាពសមាមាត្រគ្នាឬទេ? លើសពីនេះទៀត យើងត្រូវមើលថាអតិថិជនធ្លាប់មានបំណុលផ្សេងៗពីមុនមកដែរឬទេ? នៅក្នុងករណីអតិថិជនបើកអាជីវកម្ម មន្ត្រីឥណទានត្រូវសិក្សាទៅលើសកម្មភាពអាជីវកម្មរបស់អតិថិជន វិភាគឲ្យឃើញនូវចំណូលចំណាយ និងប្រាក់ចំណេញបើប្រៀបធៀបទៅនឹងប្រាក់កម្ចីដែលត្រូវសង។ ចំពោះរូបវ័ន្តបុគ្គល មន្ត្រីឥណទានត្រូវពិនិត្យទៅលើចំណូលចំណាយប្រចាំថ្ងៃ ព្រមជាមួយប្រាក់

សន្សំរបស់អតិថិជនបើប្រៀបធៀបទៅនឹងប្រាក់កម្ចីដែលត្រូវសង។

**មូលធន**(Capital)៖ សំដៅលើភាពខ្លាំងខាងហិរញ្ញវត្ថុរបស់អតិថិជនដែលស្នើសុំឥណទាន គឺរួមទាំងទ្រព្យសកម្មបម្រុងទុក។ ទ្រព្យសកម្មទាំងនោះរួមមាន សមតុល្យប្រាក់បញ្ញើនៅធនាគារផ្ទះ ដីធ្លី អាគារ និងរថយន្ត ដែលជាទ្រព្យសកម្មរូបី ហើយរីឯបទពិសោធន៍ការងារ ចំណេះដឹង និង ជំនាញផ្សេងៗជាទ្រព្យសកម្មអរូបី។ សរុបមកគឺ ដើម្បីធ្វើការវាស់វែងពីទ្រព្យសម្បត្តិរបស់អតិថិជន សម្រាប់ធានានូវលទ្ធភាពទូទាត់បំណុលនៅពេលគាត់អសមត្ថភាពសងបំណុលរយៈពេលខ្លី។

**ទ្រព្យធានា**(Collateral)៖ សំដៅលើសិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិរបស់អតិថិជនដែលស្នើ សុំឥណទាននៅពេលគាត់មិនមានលទ្ធភាពក្នុងការសងបំណុល។ ភ្នាក់ងារឥណទានត្រូវវាស់វែងពីទ្រព្យធានាដែលជាកាតព្វកិច្ចឥណទាន ដោយផ្តោតលើភាពជាម្ចាស់ទ្រព្យ តំលៃទីផ្សារនៃទ្រព្យធានា និងភាពងាយស្រួលដោះដូរទ្រព្យនានាជាសាច់ប្រាក់៕

**លក្ខខណ្ឌ**(Condition)៖ ជាផ្នែកមួយក្នុងការវិភាគឥណទាន ដែលសំដៅដល់អ្នកស្នើសុំឥណទានធ្វើឱ្យត្រូវ តាមប្រព័ន្ធសេដ្ឋកិច្ច និងព្រឹត្តការណ៍សេដ្ឋកិច្ច នឹងមានឥទ្ធិពលដល់សមត្ថភាព និងឆន្ទៈសងបំណុល។ ការងារមួយចំនួនមានការប្រែប្រួលជាខ្លាំងតាមនិន្នាការសេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក ប៉ុន្តែមានការងារខ្លះមិនសូវទទួលរងឥទ្ធិពលពីសេដ្ឋកិច្ចនោះទេ។

នៅក្នុងឥណទានអ្នកប្រើប្រាស់អ្នកវិភាគឥណទានតែងតែសង្កត់ធ្ងន់ទៅលើចរិក និងសមត្ថភាពសងបំណុល ជាជាងកត្តាផ្សេងៗទៀត ដែលទាក់ទងនឹងមូលធនរបស់អ្នកស្នើសុំឥណទាន។ អ្នកគ្រប់គ្រងឥណទានចង់បានសំណងដោយស្ម័គ្រចិត្ត (តាមឆន្ទៈ និងលទ្ធភាព)របស់អ្នកស្នើសុំ ឥណទាន ជាជាងការរឹបអូសយកទ្រព្យសម្បត្តិមកធ្វើជាកម្មសិទ្ធិវិញ។ ការយកមកធ្វើជាកម្មសិទ្ធិ វិញជាដំណើរការស្របច្បាប់ ដោយប្រកាសយកទ្រព្យធានានៅក្នុងប្រតិបត្តិការមិនទូទាត់កម្ចី។ ការទទួលបានមូលធនតាមរយៈការរឹបអូសទ្រព្យសម្បត្តិ និងតាមបណ្តាញផ្សេងៗ មានការលំបាក ណាស់ ព្រោះត្រូវចំណាយដើមទុនច្រើន និងមានឥទ្ធិពលមិនល្អសម្រាប់អ្នកផ្តល់ឥណទាន ទោះបីមានសិទ្ធស្របច្បាប់ក្នុងការរឹបអូសយកទ្រព្យសម្បត្តិលើបំណុលដែលមានស្រាប់ក៏ដោយ ក៏លទ្ធផលសំខាន់បំផុតដែលអ្នកផ្តល់ឥណទានជោគជ័យគឺ ឆន្ទៈសងរបស់អ្នកស្នើសុំឥណទាន៕

អ្នកវិភាគឥណទានជាច្រើន បានប្រកាន់ចរិតជាកត្តាសំខាន់ សម្រាប់ការវិភាគឥណទាន។ ប្រសិនបើអ្នកស្នើសុំឥណទានមានឆន្ទៈ ពួកគាត់នឹងពុះពារគ្រប់បែបយ៉ាង ដើម្បីប្រមូលចំណូល យកមកសងបំណុលគ្រប់ចំនួន ដោយមិនឱ្យមានការយឺតយ៉ាវ ផ្ទុយទៅវិញបើអ្នកស្នើសុំឥណទាន គ្មាននឆន្ទៈវិញនោះ ទោះបីពួកគាត់មានចំណូលគ្រប់គ្រាន់សម្រាប់សងបំណុលក៏ដោយ ក៏នៅតែព្យាយាមគេចវេស ឬសងយឺតយ៉ាវ។

### ១.៣.៤.ការសម្រេចចិត្ត

ការសម្រេចចិត្តផ្តល់ឥណទានធ្វើឡើងដោយអ្នកគ្រប់គ្រងឥណទាន ថាតើយល់ព្រមឬបដិសេធពាក្យស្នើសុំឥណទាន។ អ្នកគ្រប់គ្រងឥណទាននឹងសម្រេចនៅក្រោយពីការអង្កេតរួចរាល់។ ជាមូលដ្ឋានក្នុងការសម្រេចចិត្ត ការប្រើប្រាស់ 4Rs ត្រូវបានប្រើប្រាស់ជាឧបករណ៍វិភាគ។

**មនុស្សត្រឹមត្រូវ**(Right Person) សំដៅដល់ការផ្តល់ឥណទានដល់អតិថិជនដោយសង្ឃឹមថាគាត់នឹងសងត្រឡប់មកវិញទាំងដើមទាំងការទៅតាមពេលវេលាដែលបានកំណត់ជាក់លាក់។

**អាជីវកម្មត្រឹមត្រូវ**(Right Business) សំដៅដល់មុខរបរច្បាស់លាស់ ស្របច្បាប់ មានកិច្ចសន្យាច្បាស់លាស់ និងកំណត់រយៈពេលត្រឹមត្រូវ ហើយមុខរបរមានសក្តានុពលរយៈពេលវែង មាននិរន្តរភាព និងមិនមានផលប៉ះពាល់ដល់បរិស្ថាន។

**ពេលវេលាត្រឹមត្រូវ**(Right Time) សំដៅដល់ការកំណត់ពេលវេលាសម្រាប់ការណាត់ជួបដើម្បីផ្តល់ឥណទានដល់អតិថិជន។ ការកំណត់ពេលវេលានេះអាចជាជំនួយផងដែរក្នុងការសម្រេចផ្តល់ឥណទាន ដោយការពិចារណាលើការទទួលខុសត្រូវខ្ពស់របស់អតិថិជនក្នុងការកំណត់ពេលវេលាជួបគ្នា។

**ទំហំត្រឹមត្រូវ**(Right Amount) ជាការវិភាគនិងវាយតម្លៃទៅលើទំហំទុនរបស់អតិថិជនអំពីចំណូលចំណាយរបស់អតិថិជន និងលក្ខខណ្ឌខ្លះទៀតដើម្បីកំណត់ទំហំទុនថាតើគួរឲ្យខ្ចីប៉ុន្មានដែលសមរម្យ និងត្រឹមត្រូវ។

### ១.៣.៥.ការត្រួតពិនិត្យគណនី

មុខងារត្រួតពិនិត្យត្រូវបានគេប្រើប្រាស់ក្នុងការតាមដានគណនីនីមួយៗ ដើម្បីធានាឲ្យប្រាកដថាការជំពាក់សរុបគឺសមរម្យសម្រាប់អតិថិជនម្នាក់ៗ។ សកម្មភាពត្រួតពិនិត្យទាក់ទងនឹងការឃ្លាំមើលទៅលើគណនីដើម្បីបញ្ជាក់ថាការទូទាត់នឹងត្រូវបានធ្វើឡើងតាមពេលវេលាកំណត់។ សកម្មភាពត្រួតពិនិត្យនេះទាមទារឱ្យអ្នកគ្រប់គ្រងឥណទានត្រូវធ្វើបច្ចុប្បន្នភាពម្តងម្កាលទៅលើព័ត៌មានរបស់អតិថិជនដើម្បីធ្វើការសម្រេចចិត្តថាគួរបន្ថែមកំហិតលើការកំណត់នូវការចំណាយដែលអនុញ្ញាតជាមុនសម្រាប់អតិថិជន។ មានវិធីសាស្ត្រច្រើនចាំបាច់ត្រូវបង្កើតឡើងដែលអាចជួយបុគ្គលិកឥណទានក្នុងការកំណត់ទៅលើគណនីដែលធ្វើការទូទាត់យឺត។

### ១.៣.៦.ការប្រមូល

សកម្មភាពប្រមូលគឺជាការខិតខំប្រឹងប្រែងដើម្បីឲ្យអតិថិជនទូទាត់វិក័យប័ត្រ ឬបំណុលរបស់ពួកគេតាមកាលកំណត់។ កម្មវិធីប្រមូលមានប្រសិទ្ធភាព និងធ្វើឱ្យប្រសើរឡើងនូវលំហូរសាច់ប្រាក់គឺការរក្សាទំនាក់ទំនងល្អជាមួយអតិថិជននិងការបង្កើនការលក់។

សកម្មភាពនេះតម្រូវឱ្យមានការទាក់ទងទៅអតិថិជនដែលជំពាក់ហួសកាលកំណត់ ហើយដើម្បីរៀបចំការទូទាត់សងសមរម្យ និងធ្វើការស៊ើបអង្កេតបន្ថែមប្រសិនការរៀបចំមិនដំណើរការ។ ការស្រាវជ្រាវបង្ហាញពីការ

ជំពាក់កាន់តែយូរមិនបានធ្វើការទូទាត់គឺមានការពិបាកកាន់តែខ្លាំងក្នុងការប្រមូល។

## ១.៤.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

ជាធម្មតាបំណុលត្រូវបានគេធ្វើចំណាត់ថ្នាក់ខុសៗគ្នា ដោយផ្អែកទៅតាមទំហំសាច់ប្រាក់ និងរយៈពេលខ្ចី។ លើសពីនេះគេអាចផ្អែកទៅលើការសងប្រាក់ និងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី។ ធនាគារពាណិជ្ជបានធ្វើការបែងចែកចំណាត់ថ្នាក់ឥណទានជា៥ប្រភេទគឺៈ

- ឥណទានធម្មតា គឺជាឥណទានដែលអតិថិជនសងទៀតទាត់តាមកាលកំណត់រយៈពេលពី ១៥ទៅ ២៩ថ្ងៃ
- ឥណទានឃ្លាំមើល គឺជាឥណទានដែលអតិថិជនហួសកាលកំណត់សងរយៈពេលពី ៣០ទៅ៨៩ថ្ងៃ
- ឥណទានក្រោមស្តង់ដា គឺជាឥណទានដែលអតិថិជនហួសកាលកំណត់សងរយៈពេលពី ៩០ទៅ ១៧៩ថ្ងៃ
- ឥណទានសង្ស័យ គឺជាឥណទានដែលអតិថិជនហួសកាលកំណត់សងរយៈពេលពី ១៨០ទៅ៣៥៩ ថ្ងៃ
- ឥណទានបាត់បង់ គឺជាឥណទានដែលអតិថិជនហួសកាលកំណត់សងរយៈពេលពី ៣៦០ថ្ងៃឬលើសពីនេះ

## ១.៥.ការគ្រប់គ្រងហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាកំរិតនៃការគ្រោះថ្នាក់ដែលកើតឡើងចំពោះប្រាក់កំចីរបស់ធនាគារ ដោយទទួលរងនូវការខាតបង់ដោយសារអតិថិជនរបស់ខ្លួន មិនសងបំណុលតាមកិច្ចសន្យា រឺ សងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើមទាំងការ ប្រាក់ ។ ហានិភ័យនេះដែលធនាគារយកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចធ្វើអោយធនាគារក្ស័យធនបាន ដូចនេះមុននឹងសំរេចចិត្តផ្តល់ឥណទានតែងតែសិក្សាទៅលើហានិភ័យជាចំបង លុះត្រាតែធនាគារ យល់ឃើញថាគ្មានហានិភ័យ រឺ មានហានិភ័យទាបទើបធនាគារផ្តល់ឥណទាន។

### ១.៥.១.មូលហេតុដែលនាំឲ្យមានហានិភ័យឥណទាន

#### កត្តាអតិថិជន

- ព្យាករណ៍លើការវិនិយោគនៅទាប មិនមានសមត្ថភាពគ្រប់គ្រាន់
- ការពិចារណាមិនដិតដល់ទៅលើការវិនិយោគណាមួយ
- ត្រូវបានដៃគូវិនិយោគបោកប្រាស់
- អតិថិជនមានជម្ងឺ
- អតិថិជនទទួលមរណៈភាព

- ការប្រើប្រាស់កម្ចីរបស់អតិថិជនខុសគោលដៅ
- ប្រាក់កម្ចីជាន់គ្នា
- អតិថិជនមិនមានឆន្ទៈក្នុងការបង់សង
- អតិថិជនខ្ចីប្រាក់ឲ្យអ្នកដទៃ ឬចងការបន្ត
- ការចាកចេញទៅប្រកបរបររកស៊ីនៅឆ្ងាយឬចាកចោលស្រុក
- អតិថិជនមើលបំណាំគ្នា។

**កត្តាបុគ្គលិក**

- បុគ្គលិកមិនមានភាពស្មោះត្រង់
- វាយតម្លៃប្រាក់កម្ចីដោយយកមនោសញ្ចេតនាជាមូលដ្ឋាន
- ខ្វះការទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋានក្នុងការប្រមូលពត៌មាន
- ផ្តល់ប្រាក់កម្ចីហើយមិនបានត្រួតពិនិត្យតាមដានការប្រើប្រាស់ប្រាក់កម្ចីនិងក្រើនរំឭកពីការសងប្រាក់របស់អតិថិជន
- ធ្វេសប្រហែសក្នុងការវាយតម្លៃប្រាក់កម្ចីនិងមិនមានការទទួលខុសត្រូវ

**បញ្ហាក្នុងការគ្រប់គ្រង**

- ខ្វះប្រព័ន្ធត្រួតពិនិត្យ
- មិនយកចិត្តទុកដាក់ក្នុងការដោះស្រាយបំណុលហួសកាលកំណត់
- ខ្វះការចុះពិនិត្យតាមដានអតិថិជន
- ខ្វះការលើកទឹកចិត្តបុគ្គលិក
- គោលការណ៍ នីតិវិធីក្នុងការផ្តល់កម្ចីមិនសូវតឹងរ៉ឹង
- មានភាពទន់ខ្សោយក្នុងការត្រួតពិនិត្យគុណភាពឥណទាន

**អាជ្ញាធរមូលដ្ឋាន**

- មិនមានការទទួលខុសត្រូវចំពោះការចុះហត្ថលេខារបស់ខ្លួនដើម្បីទទួលបានអត្ថប្រយោជន៍ពីអតិថិជន
- ចេញលិខិតបញ្ជាក់ពីដីធ្លីលើសពីមួយច្បាប់សម្រាប់ដីមួយកន្លែងដើម្បីទទួលបានប្រយោជន៍
- គ្មានការកត់ត្រាច្បាស់លាស់

**កត្តាសង្គម និងធម្មជាតិ**

- មានសង្គ្រាម

- ការធ្លាក់ចុះនៃសេដ្ឋកិច្ច
- ការផ្លាស់ប្តូររបបនយោបាយ
- ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ។ល។

**កត្តាកូវីត១៩**

- សេដ្ឋកិច្ចមានការធ្លាក់ចុះ
- ប្រជាពលរដ្ឋមានចំណូលទាប
- ចំនួនការងារត្រូវបានកាត់បន្ថយ
- អាជីវកម្មមួយចំនួនបានផ្អាកដំណើរការ
- មានការរាំងស្ទះដល់ការធ្វើពាណិជ្ជកម្ម
- ប្រជាពលរដ្ឋមានហានិភ័យក្នុងការឆ្លងជម្ងឺ។

### ១.៥.២.ផលប៉ះពាល់ដែលបណ្តាលមកពីហានិភ័យឥណទាន

នៅពេលដែលហានិភ័យឥណទាន មានទំហំកាន់តែធំឡើងៗ នោះនាំឲ្យមានផលប៉ះពាល់ទៅលើកត្តាផ្សេងៗដូចខាងក្រោមៈ

- បង្កើនចំណាយបន្ថែមសម្រាប់ប្រតិបត្តិការ
  - ភ្នាក់ងារចំណាយពេលច្រើនដើម្បីតាមដានលើហានិភ័យឥណទាននោះ
  - ភ្នាក់ងារមិនមានពេលសម្រាប់បញ្ចេញឥណទានថ្មីទៀត
  - ត្រូវចំណាយផ្សេងៗជាច្រើនទៀតដូចជា ក្រដាសស្នាម ប្រេងឥន្ធនៈ ថ្លៃប្រថាប់ត្រា និងការរត់ការផ្សេងៗ។
- ខូចកេរ្តិ៍ឈ្មោះធនាគារ
  - ក្រមសីលធម៌ភ្នាក់ងារអាចនឹងធ្លាក់ចុះនៅពេលដែលមានវិវាទកើតឡើង
  - បុគ្គលិកអាចមិនស្តាប់បង្គាប់អ្នកគ្រប់គ្រង ព្រោះអស់សង្ឃឹមក្នុងវិជ្ជាជីវៈ
  - អតិថិជនមិនមានជំនឿលើធនាគារហើយមិនហ៊ានមកប្រើសេវាកម្មរបស់ធនាគារ
  - អតិថិជនធ្លាប់សងទៀងទាត់ បែរជាមិនទៀងទាត់តាមគេតាមឯង។
- សរុបផលប៉ះពាល់
  - បាត់បង់ទីផ្សារ
  - ចំណូលពីការប្រាក់ថយចុះ
  - ប្រាក់ចំណេញរបស់ធនាគារទាប

- ➢ គ្មានមូលនិធិសងការប្រាក់
- ➢ អតិថិជនប្រាក់បញ្ញើដកប្រាក់ចេញពីធនាគារ
- ➢ ធនាគារនឹងក្ស័យធនឆាប់ៗ
- ➢ បុគ្គលិកគ្មានការងារធ្វើ។ល។

### ១.៥.៣.យុទ្ធសាស្រ្តកាត់បន្ថយហានិភ័យឥណទាន

វាយតម្លៃអតិថិជនឲ្យបានត្រឹមត្រូវទៅលើ

- ❖ គោលបំណងនៃការសុំខ្ចី
- ❖ ពិនិត្យមើលលើអាជីវកម្មរបស់អ្នកសុំខ្ចី
- ❖ វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
- ❖ ពិនិត្យលើប្រវត្តិរូបរបស់អ្នកខ្ចី
- ❖ ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា

ពង្រឹងសមត្ថភាពបុគ្គលិក

- ❖ ជ្រើសរើសបុគ្គលិកដែលមានជំនាញខាងឥណទាន
- ❖ ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកជាការចាំបាច់
- ❖ ដាក់ទោសទៅលើបុគ្គលិកដែលមានកំហុស
- ❖ លើកទឹកចិត្តរាល់បុគ្គលិកដែលធ្វើការងារបានល្អ។

### ១.៥.៤.ឥណទានមានបញ្ហាដំណោះស្រា

ទោះបីធនាគារព្យាយាមការពារសុវត្ថិភាពប្រាក់ឱ្យខ្ចីយ៉ាងណាក៏ដោយ ក៏ប្រាក់ឱ្យខ្ចីខ្លះក្លាយ ទៅជាប្រាក់ឱ្យខ្ចីមានបញ្ហាដោយចៀសពុំរួច។

ជំហានសំខាន់ក្នុងការដោះស្រាយបំណុលមានបញ្ហាមានដូចខាងក្រោមៈ

- ❖ ធ្វើការរាយការណ៍ភ្លាមៗនៅពេលមានការសង្ស័យថាឥណទានមានបញ្ហា ដើម្បីរកដំណោះស្រាយ
- ❖ ធ្វើការកំណត់ពីមូលហេតុនៃបញ្ហា ដើម្បីដឹងថាវាជាបញ្ហាផ្នែកខាងក្នុង ឬផ្នែកខាងក្រៅ ឬមូលហេតុបណ្តាលមកពីអតិថិជន
- ❖ នៅពេលដែលមានបញ្ហាមកពីអតិថិជន ធនាគារអាចធ្វើការទាមទារប្រឆាំងនិងអ្នកខ្ចី ឬព្យាយាមទាមទារពីអ្នកធានា
- ❖ ធនាគារអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ដើម្បីឲ្យធនាគារមានសិទ្ធលើទ្រព្យដែលអតិថិជនបានដាក់ទ្រព្យធានា។

## ១.៦.សារៈសំខាន់នៃធនាគារពាណិជ្ជ

ធនាគារពាណិជ្ជមានសារៈសំខាន់ដូចជា៖

- សម្រួលដល់ការផ្ទេរសាច់ប្រាក់ពីកន្លែងមួយទៅកន្លែងមួយទៀត
- លើកកម្ពស់ដល់ជីវភាពប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចីឥណទាន
- ជាកន្លែងជួយរក្សាប្រាក់របស់ប្រជាពលរដ្ឋឲ្យមានសុវត្ថិភាពនៅពេលផ្ញើរ
- ជាចលករមួយក្នុងការជម្រុញសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន
- ផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុងការទូទាត់ឬផ្ទេរប្រាក់
- ជាកន្លែងផ្តល់ទុនក្នុងការពង្រីកអាជីវកម្មឬសម្រាប់ប្រើប្រាស់ផ្សេងៗដល់បុគ្គលឬក្រុមហ៊ុន។

# ជំពូកទី២

# លក្ខណៈទូទៅនៃការបង្កើតធនាគារពាណិជ្ជ

## ២.១.លក្ខខណ្ឌតម្រូវចំពោះភាគទុនិក និងគណៈគ្រប់គ្រង

ដើម្បីដំណើរការរលូននៃប្រពន្ធ័ធនាគារ ការផ្តល់សុវត្ថិភាពគ្រប់គ្រាន់ដល់សាធារណជន និងភាពអាចទុកចិត្តបាន គឺជាផ្នែកមួយសំខាន់ណាស់ ដូច្នេះហើយធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរនិងអាណាព្យាបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តម្រូវឲ្យភាគទុនិក គណៈគ្រប់គ្រង សំខាន់ៗនៃគ្រឹះស្ថានធនាគារត្រូវបង្ហាញ និងបញ្ជាក់ស្ថានភាពពិត ប្រាកដរបស់ខ្លួន ដូចជា៖ ដើមទុននៃធនាគារ ភាពស្មោះត្រង់ ភាពសុចរិត ភាពត្រឹមត្រូវ ការសិក្សា ចំណេះដឹង សមត្ថភាព ព្រមទាំងស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិក។

### ២.១.១.ភាគទុនិក

ភាគទុនិកមួយ ឬច្រើនត្រូវមានភស្តុតាងបង្ហាញថាមានបទពិសោធន៍ក្នុងសកម្មភាពដែលគ្រឹះស្ថានធនាគារមាន បំណងធ្វើប្រតិបត្តិការ។ អាជ្ញាធរអាណាព្យាបាល នឹងពិនិត្យមើលនូវ៖

- គុណភាពនៃអ្នកចូលហ៊ុននិងស្ថានភាពពិតប្រាកដខាងហិរញ្ញវត្ថុរបស់អ្នកទាំងនោះ
- សម្បទានៃអ្នកចូលហ៊ុនសំខាន់ៗដើម្បីគោរពរួមគ្នាកាតព្វកិច្ចដែលតម្រូវដល់អ្នកទាំងនោះក្នុងករណីចាំបាច់
- បង្កើនបង្គ្រប់តាមវិធីណាមួយ នូវមូលនិធិរបស់ធនាគារ។
- ភាពសមស្របនៃមធ្យោបាយធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដោយមានកម្ម វិធីសកម្មភាពភ្ជាប់ជាមួយ។

#### ២.១.១.១.ការព្រមព្រៀងរបស់ភាគទុនិក

ភាគទុនិក ចាំបាច់ត្រូវតែមានការព្រមព្រៀងគ្នាយ៉ាងពិតប្រាដកពីអ្នកដែលចូលរួមភាគទុនទាំងអស់ក្នុងការដាក់ ភាគទុន ដោយគ្មានការភន្ត័ច្រឡំ គ្មានការបន្លំបោកប្រាស់ និងគ្មានការគំរាមកំហែងឡើយ។ ពោលគឺបង្ហាញឆន្ទៈក្នុង ការដាក់ភាគទុន ដោយគ្មានការបង្ខិតបង្ខំ គម្រាមកំហែងពីបុគ្គលណាមួយឡើយ ហើយពុំមែនស្ថិតក្នុងស្ថានភាព ដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ នូវសកម្មភាពរបស់ខ្លួនតាមផ្លូវច្បាប់ឡើយ។

### ២.១.១.២.អត្តសញ្ញាណរបស់ភាគទុនិក

[6]ភាគទុនិកដែលកាន់កាប់៥%ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ព័ត៌មានដូចតទៅៈ

- ❖ ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាលនិង លក្ខន្តិកៈ។ ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់នាម គោត្តមនាម ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ និងលំនៅឋាន ត្រូវបញ្ជាក់ថាតើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ធនាគារឬទេ។ បើមែនត្រូវធានាថាសមាជិកនោះមិនមានពាក់ពន្ធ័ជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា១៨នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ។ សម្រាប់គោលបំណងទាំងអស់នេះ បុគ្គលពាក់ព័ន្ធម្នាក់ៗត្រូវបំពេញជីវប្រវត្តិនិងសំណួរដូចមានក្នុងឧបសម្ព័ន្ធ។
- ❖ បញ្ជាក់ពីចំនួន និងភាគរយនៃភាគកម្មដែលបានស្មើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត។ រៀបរាប់លំអិតពីការសម្របសម្រួលខាងគតិយុត្តិ និងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលប័ត្រ។ បើភាគទុននិកជាឯកត្តជនត្រូវបញ្ជាក់ច្បាស់ពីប្រភពដើមនៃដើមទុនវិនិយោគ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការ ស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែក ដែលអនុវត្តចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ។ ហើយតើទម្រង់ បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ។
- ❖ បញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ភាគទុនិក។ បើចាំបាច់ត្រូវរៀបរាប់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនដើម និងរបស់ក្រុមហ៊ុនហូលឌិញជាកណ្តាល បង្ហាញនូវសមាមាត្រភាគហ៊ុន និងសិទ្ធិបោះឆ្នោត។ ត្រូវរៀបចំបញ្ជីឈ្មោះអ្នកចាត់ការធំៗនៃអ្នកចូលហ៊ុន។
- ❖ រៀបរាប់ពីសកម្មភាពរបស់ភាគទុនិក។ ប្រសិនបើភាគទុនិកជាសមាជិកនៃក្រុមមួយត្រូវពិពណ៌នាពី អង្គភាពធំៗនៃក្រុមនោះ រួមជាមួយអង្គការលេខផង។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកមានទ្រព្យសម្បត្តិច្រើននៅ ក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ។ បញ្ជាក់ថាតើក្រុមណាដែលជាម្ចាស់កម្មសិទ្ធិផ្ទាល់របស់ភាគទុនិកៈមានទុន ច្រើននៅក្នុងគ្រឹះស្ថានឥណទានឬទេ បើមានត្រូវរៀប រាប់ឲ្យអស់។
- ❖ ប្រាប់ថាភាទុនិក និងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហរិញ្ញវត្ថុឬទេ។ បើមានត្រូវបញ្ជាក់ថាក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណា ឬអាជ្ញាធរណា។
- ❖ បញ្ជក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុង និងពីខាងក្រៅរបស់ភាគទុនិក។
- ❖ បញ្ជាក់ថា តើក្នុងរយៈពេល១០ឆ្នាំកន្លងមក ភាគទុនិកបានទទួលរងនូវការស៊ើបអង្កេតឬទទួល រងនូវការពិន័យ ជាសំភារៈតាមទ្រង់ការរដ្ឋាជីវៈរដ្ឋបាល ឬតុលាការនៅកម្ពុជា ឬនៅបរទេសឬទេ។ ត្រូវ

[6] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, លេខធ៧-០០-១៤ ប្រក, ១០ មករា ២០០០, ប្រការ៥

រៀបរាប់ថា តើមានបានទទួល ទណ្ឌកម្មណាមួយដោយសារការស៊ើបអង្កេត ឬទម្រង់ការឬទេ។ បញ្ជាក់ដែរថា តើភាគទុនិកជាកម្មវត្ថុ ឬអាចជា កម្មវត្ថុនៃទម្រង់ការរដ្ឋបាល យុត្តិធម៌ ឬជាមិត្តភាព នៅកម្ពុជា ឬនៅបរទេសដែលអាចមានឥទ្ធិពលខាងសំភារៈទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ភាគទុនិកនេះ ឬទេ។

- ❖ ប្រាប់ពីគោលដៅរបស់ភាគទុនិក ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែល បានដាក់ពាក្យសុំអាជ្ញាបណ្ណ និងផ្តល់ព័ត៌មានដែលពាក់ពន្ធ័ទាំងអស់។
- ❖ បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិក និងអ្នកដាក់សុំឬទេ ហើយតើទំនាក់ទំនង ទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា។
- ❖ បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគនិកនៅកម្ពុជាមានអ្វីខ្លះ ហើយទំនាក់ ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត។
- ❖ ផ្ញាប់គណនីនានារបស់ភាគទុនិក ឬក្រុមហ៊ុនដើមរបស់ខ្លួនសំរាប់រយៈពេល៣ឆ្នាំចុងក្រោយ ព្រមទាំងធ្វើការព្យាករណ៍សំរាប់ឆ្នាំនេះ។ បើសិនភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្តល់ពត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

### ២.១.២.គណៈគ្រប់គ្រង

គណៈគ្រប់គ្រងនៃធនាគារពាណិជ្ជ រួមមាន ក្រុមប្រឹក្សាភិបាលឯករាជ្យនិងសកម្ម គណៈប្រតិបត្តិ និងគណៈ កម្មការជំនាញ ដែលចាំបាច់ប្រកបដោយគុណវឌ្ឍិ សមត្ថភាព សុចរិតភាព ដើម្បីដឹកនាំ គ្រប់គ្រងគ្រឹះស្ថានឲ្យ មានប្រសិទ្ធិភាព។

#### ២.១.២.១.ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាបុគ្គលដែលមានសិទ្ធិអំណាចខ្ពស់ក្នុងការសម្រេចអំពីជោគវាសនារបស់ធនាគារ ព្រមទាំងទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការគ្រប់គ្រង និងស្ថានភាព របស់គ្រឹះស្ថានក្នុងនាមភាគទុនិក។ សម្រាប់ធនាគារពាណិជ្ជ លើកលែងតែសាខាធនាគាបរទេស ក្រុមប្រឹក្សាត្រូវមានចំនួនសមាជិកឯករាជ្យយ៉ាងតិច២(ពីរ) រូប។[7]

#### ក.អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវមានជីវប្រវត្តិ និងត្រូវឆ្លើយសំនួរដូចមានក្នុងឧបសម្ពន្ធ័ ព្រមទាំងត្រូវមានរបាយការណ៍ បញ្ជាក់ថា គ្មានអ្នកណាម្នាក់ពាក់ពន្ធ័ទៅនឹងការហាមឃាត់។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានបទពិសោធន៍ ខាងឥណទានយ៉ាងតិចបំផុត៣ឆ្នាំ ហើយត្រូវមានបញ្ជាក់ក្នុងជីវប្រវត្តរបស់សមាជិកនោះ។

[7] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ២

**ខ.គុណវុឌ្ឍិនៃសមាជិកក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ហើយសមាជិកទាំងនេះត្រូវ[8] ៖

- ឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របមួយដោយធនាគារជាតិនៃកម្ពុជា ដែលជាផ្នែកមួយ នៃការផ្តល់អាជ្ញាបណ្ណ
- យល់ពីតួនាទីរបស់ខ្លួន រួមទាំងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន
- ប្រើចំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដើម្បីរក្សាបានជំនាញរួមគ្នា
- យល់ពីភារកិច្ចរបស់ខ្លួនចំពោះភាគទុនិក ចំពោះគ្រឹះស្ថាន និងចំពោះអ្នកដែល មានផល ប្រយោជន៍ពាក់ពន្ធ័
- យល់ដឹងពីបរិស្ថានច្បាប់និងបទបញ្ញត្តិទាំងមូលដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើងតាមដានស្ថានភាពទីផ្សារបច្ចុប្បន្ន និងយល់ដឹងពីបរិស្ថានប្រគួតប្រជែងនៃអាជីវកម្មរបស់គ្រឹះស្ថាន មានពេលវេលា និងថាមពលដែលអាចបំពេញការងារប្រកបដោយប្រសិទ្ធិភាព។

**គ.តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវសកម្មក្នុងការងារហើយយ៉ាងហោចណាស់សមាជិកទាំងនេះត្រូវ[9]៖

- អនុម័តយុទ្ធសាស្ត្រ គោលនយោបាយហានិភ័យ និងនីតិវិធីគ្រប់គ្រងហានិភ័យទាំងនោះរៀបចំរចនាសម្ពន្ធ័របស់ខ្លួនដើម្បីឲ្យការពិភាក្សាមានប្រសិទ្ធិភាពជ្រើសរើស ត្រួតពិនិត្យ ផ្លាស់ប្តូរនាយកប្រតិបត្តិ
- សាកសួរអ្នកគ្រប់គ្រងជាន់ខ្ពស់
- រៀបចំប្រព័ន្ធរាយការណ៍មួយ ដែលអាចជួយឲ្យការអនុវត្តកាតព្វកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលមានលក្ខណៈយល់ដឹងបាន និងទាន់ពេលវេលា
- វាយតម្លៃការប្រតិបត្តិរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ឲ្យបានទៀងទាត់
- អនុវត្តនូវការវិនិច្ឆ័យសម្រាប់ពេលអនាគត ដើម្បីសំគាល់ នូវបញ្ហាជាសក្តានុពល ដែល គ្រឹះស្ថានត្រូវប្រឈម និងធានាថាសកម្មភាពកែតម្រូវសមស្របត្រូវបានអនុវត្តជាប្រចាំបើចាំបាច់។
- សមាជិកក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ សមាជិកក្រុមប្រឹក្សាភិបាលនឹងត្រូវដកចេញពីតំណែងក្នុងករណីដែលបុគ្គលនោះមិនបានចូលរួមអង្គប្រជុំក្រុមប្រឹក្សាភិបាលបីដងជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ។

[8] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៣

[9] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៤

- ក្រុមប្រឹក្សាភិបាលត្រូវជូនមកធនាគារជាតិនៃកម្ពុជា ជាបន្ទាន់រាល់ការផ្លាស់ប្តូរកម្មសិទ្ធិភាគហ៊ុននិងឬ/សិទ្ធបោះឆ្នោតនៅក្នុងគ្រឹះស្ថាន។ កាតព្វកិច្ចជូនដំណឹងនេះមិនត្រូវធ្វើឡើងចំពោះតែការផ្លាស់ប្តូរការកាន់កាប់ដើម ទុនឈានដល់៥ %២០%ឬនៃសិទ្ធិបោះឆ្នោតទេ ប៉ុន្តែការជូនដំណឹងក៏ត្រូវធ្វើឡើងចំពោះការផ្លាស់ប្តូរដែលប៉ះពាល់ ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រសិទ្ធិភាពនៃការគ្រប់គ្រងរបស់គ្រឹះស្ថាន តាមរយៈការកាន់កាប់សមាមាត្រភាគហ៊ុន ឬនៃសិទ្ធិបោះឆ្នោត។ ការជូនដំណឹងនេះជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដោយមិនគិតដល់កាតព្វកិច្ចដែលតម្រូវដោយបទបញ្ញត្តិផ្សេងទៀតពាក់ពន្ធ័ភាគហ៊ុនថ្មី ឬភាគហ៊ុនដែលបានផ្ទេរ និង/ឬសិទ្ធនៃការបោះឆ្នោត។

**២.១.២.២.គណៈប្រតិបត្តិ**

គណៈប្រតិបត្តិ ជាក្រុមបុគ្គលដែលទទួលខុសត្រូវលើការគ្រប់គ្រងដោយមានប្រសិទ្ធិភាពលើគ្រឹះស្ថាន។ គណៈប្រតិបត្តិម្នាក់ក្នុងចំណោពីររូបដែលត្រូវបានតែងតាំងក្នុងតំណែងគ្រប់គ្រងត្រូវផ្តល់ពត៌មានដូចមាន ដោយបំពេញជីវប្រវត្តិ និងសំនួរដូចមានចែងក្នុងឧបសម្ពន្ធ័ ។

**ក.អត្តសញ្ញាណរបស់នាយកចាត់ការ**

នាយកចាត់ការគប្បីបំពេញនូវបែបបទដូចខាងក្រោម[10] ៖

- នាម និងគោត្តនាម
- ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត
- សញ្ជាតិ
- អាស័យដ្ឋានផ្ទាល់ខ្លួន(ត្រូវមានទីកន្លែងស្នាក់នៅក្រោយពេលទទួលបានការតែងតាំង បើមានការផ្លាស់ប្តូរ និងមានកន្លែងស្នាក់នៅជិតកន្លែងសំខាន់សម្រាប់ធ្វើអាជីវកម្ម ដូចជានៅក្នុងប្រទេសកម្ពុជា)។

**ខ.គុណវុឌ្ឍិ និងបទពិសោធន៍របស់នាយកចាត់ការ**

នាយកចាត់ការត្រូវមានសញ្ញាប័ត្រ ក៏ដូចជាថ្ងៃខែឆ្នាំ និងទីកន្លែងទទួលសញ្ញាប័ត្រ។ បញ្ជាក់ពីមុខតំណែងដែលបានកាន់កាប់រយៈពេល១០ឆ្នាំចុងក្រោយដោយមានឈ្មោះទីកន្លែង និងសកម្មភាពរបស់និយោជក និងប្រភេទបទពិសោធន៍ ទទួលលបាន និងកម្រិតទទួលខុសត្រូវ។[11]

**២.១.២.៣.គណៈកម្មការជំនាញ**

គណៈកម្មការជំនាញ គឺមនុស្សមួយក្រុមដែលក្រុមប្រឹក្សាភិបាលបង្កើតឡើង ដើម្បីគ្រប់គ្រងដំណើរនៃគ្រឹះស្ថាន។

[10] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខក៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៦ក

[11] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខក៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៦ខ

**ក.គណៈកម្មការសវនកម្ម**

គ្រឹះស្ថានត្រូវបង្កើតគណៈកម្មការសវនកម្មមួយ ដែលត្រូវដឹកនាំដោយសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះ ត្រូវមានយ៉ាងតិចបុគ្គលឯករាជ្យម្នាក់ដែលមានជំនាញឯកទេសផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ និងបុគ្គលឯករាជ្យម្នាក់ ដែលមានឯកទេសផ្នែកច្បាប់ និងធនាគារ។

**ខ.ការទទួលខុសត្រូវរបស់គណៈកម្មការសវនកម្ម**

គណៈកម្មការសវនកម្មត្រូវទទួលខុសត្រូវជាអប្បរមាដោយ[12] ៖

- ធានាថាព័ត៌មានដែលបានផ្ដល់ជូនសាធារណជន ធនាគារជាតិនៃកម្ពុជាត្រឹមត្រូវ និងអាចជឿជាក់បាន។
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យដែលបានប្រើដើម្បីរៀបចំគណនីដោយឡែកនិងគណនីរួមបញ្ចូលគ្នា ប្រសិនបើមាន។
- វាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃថា តើប្រពន្ធ័សម្រាប់ វាស់វែងតាមដាន និង ត្រួតពិនិត្យហានិភ័យមានសង្គតិភាព និងផ្ដល់អនុសាសន៍លើសកម្មភាព អនុវត្តបន្តនៅពេលណាដែលសមស្រប។

**គ. គណៈកម្មការហានិភ័យ**

គណៈកម្មការហានិភ័យរបស់គ្រឹះស្ថាន ត្រូវដឹកនាំដោយបុគ្គលដែលមានជំនាញខាង ហិរញ្ញវត្ថុ និងគ្រប់គ្រង ហានិភ័យ។ បុគ្គលនោះត្រូវមានឯករាជ្យពីការងារគ្រប់គ្រងប្រតិបត្តិការ ប្រចាំថ្ងៃ។ គណៈកម្មការហានិភ័យត្រូវ ទទួលខុសត្រូវជាអប្បរមា លើការតាមដានត្រួតពិនិត្យ ការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ ដែលកំណត់ ដោយក្រុមប្រឹក្សាភិបាល។[13]

## ២.២.នីតិវិធីនៃការបង្កើត

ដើម្បីទទួលបាននូវអាជ្ញាប័ណ្ណ ធនាគាពាណិជ្ជត្រូវបំពេញល័ក្ខខ័ណ្ឌមួយចំនួន និងសំណុំបែបបទស្នើសុំ អាជ្ញាប័ណ្ណដែលតម្រូវដោយអាជ្ញាធរអាណាព្យាបាល។ បែបបទសុំអាជ្ញាប័ណ្ណត្រូវស្នើដោយបុគ្គលដែលទទួល បានការអនុញ្ញាតជាលាយលក្ខណ៍អក្សរត្រឹមត្រូវ។

### ២.២.១.ល័ក្ខខ័ណ្ឌក្នុងការផ្តល់អាជ្ញាប័ណ្ណ

ល្ដឹកណាមិនទាន់ទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរអាណាព្យាបាល ធនាគាពាណិជ្ជពុំមានសិទ្ធិធ្វើប្រតិបត្តិ ការណ៍របស់ខ្លួនបានឡើយ។

[12] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៨
[13] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៨-២១១ ប្រក, ២៥ វិច្ឆិកា ២០០៨, ប្រការ៩

### ២.២.១.១.ការដាក់ពាក្យសុំ និងការផ្តល់អាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណ អាចស្នើសុំដោយអ្នកចាត់ការ ឬបុគ្គលដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ ហើយត្រូវរៀបរាប់ ដូចខាងក្រោម[14] ៖

- ❖ នាម ឬនាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន
- ❖ អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាបើជាក្រុមហ៊ុនបរទេស រូបភាពគតិយុត្តិ និងលក្ខន្តិកៈ ឬ ឯកសារបង្កើតផ្សេងៗ
- ❖ ចំនួនដើមទុនដែលមានស្រាប់ ឬដើមទុនដែលបានគ្រោង ឬចំនួនដើមទុនដែលត្រូវបង់ ក្នុងករណីជាសាខា ក្រុមហ៊ុនបរទេស ហើយចំនួននេះយ៉ាងតិចបំផុតត្រូវស្មើនឹងចំនួនដើមទុនអប្បរមា។
- ❖ ការបែងចែកភាគទុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងអាចមានរវាងភាគទុនិកដែលដើរតួនាទីក្នុងការដឹកនាំ គោលនយោបាយធនាគារ
- ❖ អត្តសញ្ញាណ និងជីវប្រវត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលព្រមទាំងបញ្ជាក់ថាគ្មាននរណាម្នាក់ស្ថិតក្នុងការ ហាមឃាត់ដោយសារធ្លាប់បានប្រព្រឹត្តបទល្មើសឡើយ ពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេល៣ឆ្នាំទៅមុខដូចជា ៖ ទំហំនៃការខ្ចីគ្រប់ប្រភេទ ប្រភេទនិងទំហំ សេវាផ្សេងទៀត(ជាគណនីសន្សំ បញ្ញើ ឬមធ្យោបាយទូទាត់) ប្រភេទអតិថិជន ព្រមទាំងប្រភពនៃធនធានដែលបានគ្រោងទុកជាដើម។

ក្រោយពីបានបំពេញបែបបទដោយមានសំណុំលិខិតគ្រប់គ្រាន់ដែលតម្រូវដោយអាជ្ញាធរអាណាព្យាបាល ធនាគាជាតិនឹងធ្វើការសម្រេចក្នុងរយៈពេល៦ខែ គិតពីពេលទទួលពាក្យស្នើសុំ ដោយជូនដំណឹងជាលាយលក្ខណ៍ អក្សរអំពីការសម្រេចនេះ។ ក្នុងករណីមានការចាំបាច់ធនាគារជាតិនិងកំណត់នូវល័ក្ខខ័ណ្ឌ និងរយៈពេលនៃការ អនុវត្តលិខិតអនុញ្ញាត ហើយបើអនុវត្តពុំបានទាន់ពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យាពេល និងមានការយល់ព្រមពីធនាគាជាតិ។[15]

ម៉្យាងទៀត អាជ្ញាប័ណ្ណដែលផ្តល់អោយដោយធនាគាជាតិដល់ធនាគាពាណិជ្ជនោះមិនមានកំណត់រយៈពេលសុពលភាពនោះឡើយ។ មានន័យថា អាជ្ញាប័ណ្ណដែលទទួលបាននោះអាចយកទៅប្រើប្រាស់បានជានិរន្តន៍ ដោយពុំចាំបាច់ស្នើសុំម្តងទៀតទេ គ្រាន់តែបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ តាមការកំណត់របស់អាជ្ញាធរ អាណាព្យាបាល ជាការស្រេច។

---

[14] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, លេខធ៧-០០-១៤ ប្រក, ១០ មករា ២០០០, ប្រការ៤

[15] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, លេខធ៧-០០-១៤ ប្រក, ១០ មករា ២០០០, ប្រការ៨

#### ២.២.១.២.ដើមទុន និងប្រាក់បម្រុងកាតព្វកិច្ច

ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេសដែលមានធនាគារមេមានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ២០០,០០០,០០០,០០០។ ចំពោះអត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុកឬជាបុត្តសម្ព័ន្ធធនាគារបរទេសត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០,០០០,០០០,០០០។[16]

ចំពោះប្រាក់បម្រុងកាតព្វកិច្ចរូបិយប័ណ្ណបរទេស (ជាពិសេស ប្រាក់ដុល្លារអាមេរិក) និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ផ្សេងគ្នា ។ អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយបណ្ណបរទេស និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ក្នុងអត្រា១២,៥% និង ៨% រៀងគ្នា ។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសចំនួន ១២,៥% ក្នុងនោះ ៤,៥% ត្រូវបានផ្តល់ការប្រាក់ដោយធនាគារជាតិនៃកម្ពុជា និង ៨% បន្ថែមទៀត មិនត្រូវបានផ្តល់ការប្រាក់ទេ ។ ចំពោះប្រាក់បម្រុងកាតព្វកិច្ចជារៀល ក៏មិនត្រូវបានផ្តល់ការប្រាក់ដែរ។[17]

### ២.២.២.សោហ៊ុយលើសេវាអាជ្ញាប័ណ្ណ

#### ២.២.២.១.តម្លៃសិក្សាអាជ្ញាប័ណ្ណ

អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតជាទឹកប្រាក់ចំនួន ៣,៥០០,០០០រៀលនៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ។[18]

#### ២.២.២.២.សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ

ចំពោះធនាគារពាណិជ្ជត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំឲ្យបានមុនថ្ងៃទី ១៥ ខែ មករារៀងរាល់ឆ្នាំនៅធនាគារជាតិនៃកម្ពុជាអាស្រ័យតាម[19]៖

- ទីស្នាក់ការកណ្តាល ត្រូវបង់៧០,០០០,០០០រៀល
- សាខាទី៧ចុះ ត្រូវបង់៥៦,០០០,០០០រៀលក្នុងមួយសាខា
- សាខាទី៨ឡើង ត្រូវបង់២០,០០០,០០០រៀលក្នុងមួយសាខា
- សាខាស្រុក ត្រូវបង់១,០០០,០០០រៀលក្នុងមួយសាខា

---

[16] ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០១៦-១១៧ ប្រក, ២២ មីនា ២០១៦, ប្រការ៣

[17] ប្រកាសស្តីពីប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ, លេខធ៧-០១៨-២៨២ ប្រក, ២៩ សីហា ២០១៨, ប្រការ១

[18] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, លេខធ៧-០០-១៤ ប្រក, ១០ មករា ២០០០, ប្រការ១០

[19] ប្រកាសស្តីពីសោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខធ៧-០៤-២០៥ ប្រក, ២៩ ធ្នូ ២០០៤, ប្រការ២ក

## ២.៣.ប្រភពមូលនិធិរបស់ធនាគារពាណិជ្ជ

ប្រភពមូលនិធិរបស់ធនាគារពាណិជ្ជមាន៖

### ២.៣.១.ប្រាក់បញ្ញើអតិថិជន

ជាមូលធនដែលត្រូវបានផ្តល់ដោយសាធារណជនទៅឲ្យធនាគារក្រោមកិច្ចសន្យាមួយ។

#### ២.៣.១.១.ប្រាក់បញ្ញើតាមតម្រូវការ

- មានសមតុល្យខ្ពស់
- គ្មានការប្រាក់
- អាចដកប្រាក់និងដាក់ប្រាក់បានតាមតម្រូវការ
- អាចទូទាត់ថ្លៃទំនិញនិងសេវាកម្មតាមមូលប្បទានប័ត្រ
- អាចទូទាត់ថ្លៃទំនិញនិងសេវាកម្មតាមប័ណ្ណVisa Card ឬ Master Card
- បណ្តាក្រុមហ៊ុនឬបុគ្គលផ្ញើនៅធនាគារដើម្បីពឹងធនាគាររក្សានិងទូទាត់ជំនួស។

#### ២.៣.១.២.ប្រាក់បញ្ញើសន្សំ

- មានសមតុល្យទាប
- អាចដកប្រាក់និងដាក់ប្រាក់បានតាមគោលនយោបាយរបស់ធនាគារនីមួយៗ
- អាចដកប្រាក់និងទូទាត់ថ្លៃទំនិញតាមប័ណ្ណ ATM តាមគោលនយោបាយរបស់ធនាគារនីមួយៗ
- អ្នកផ្ញើប្រាក់ ដាក់ប្រាក់សន្សំជាមួយធនាគារដើម្បីរក្សាប្រាក់និងបង្កើតចំណូលពីផ្នែកប្រាក់សន្សំនេះ។

#### ២.៣.១.៣.ប្រាក់បញ្ញើមានកាលកំណត់

- មានទំហំទឹកប្រាក់ជាក់លាក់
- មានការប្រាក់ខ្ពស់
- មានរយៈពេលកំណត់ជាក់លាក់ដោយអ្នកផ្ញើរប្រាក់មិនអាចដកមុនកាលកំណត់បានឡើយ

### ២.៣.២.កម្ចីពីប្រភពមិនមែនប្រាក់បញ្ញើ

#### ២.៣.២.១.កម្ចីពីធនាគារជាតិឬធនាគារកណ្តាល

ជាផ្នែកប្រាក់កម្ចីដើម្បីដោះស្រាយនូវតម្រូវការមូលនិធិបន្ទាន់ក្នុងការប្រើប្រាស់មូលនិធិរបស់ធនាគារពាណិជ្ជ ក្នុងករណីដែលខ្វះខាតសាច់ប្រាក់បម្រុងធនាគារពាណិជ្ជតែងតែខ្ចីលុយពីធនាគារកណ្តាល។

#### ២.៣.២.២.កម្ចីពីស្ថាប័នហិរញ្ញវត្ថុដទៃទៀត

ជាប្រភពមួយដែលបណ្តាធនាគារពាណិជ្ជខ្ចីគ្នាទៅវិញទៅមកនិងខ្ចីពីស្ថាប័នហិរញ្ញវត្ថុដទៃទៀតលើទីផ្សារអន្តរធនាគារ។

#### ២.៣.២.៣.កម្ចីពីទីផ្សារមូលធន

ធនាគារពាណិជ្ជអាចខ្ចីមូលនិធិពីទីផ្សារមូលធនបានតាមរយៈការបោះផ្សាយនូវឧបករណ៍បំណុលដូចជា សញ្ញាប័ណ្ណនៅលើទីផ្សារមូលធនជាដើម។

### ២.៣.៣.មូលធនផ្ទាល់ខ្លួនរបស់ភាគទុនិក

- មុននឹងចាប់ផ្តើមអាជីវកម្មចំពោះធនាគារពាណិជ្ជត្រូវមានដើមទុនផ្ទាល់របស់កម្មសិទ្ធិករក្នុងកម្រិតណាមួយដើម្បីបង្កើតទំនុកចិត្តចំពោះអតិថិជន
- តាមប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតម្រូវឲ្យធនាគារពាណិជ្ជមានដើមទុនអប្បបរមាចំនួន២០០,០០០,០០០,០០០រៀល។

## ២.៤.ធនាគារពាណិជ្ជក្នុងប្រទេសកម្ពុជា

យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា គិតត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ធនាគារពាណិជ្ជដែលកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជាមានចំនួន៥១ធនាគារ។

# ជំពូកទី៣

# ការគ្រប់គ្រងឥណទាន

## ៣.១. គោលបំណងនៃការគ្រប់គ្រង

ធនាគារពាណិជ្ជគឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្តល់សេវាកម្មសម្រាប់ទាំងអ្នកសន្សំ និងអ្នកខ្ចី។ តួនាទីរបស់ពួកគេនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ក្នុងការរក្សាប្រាក់។ គោលបំណងចម្បងរបស់ធនាគារពាណិជ្ជ គឺដើម្បីស្វែងរកប្រាក់ចំណេញបើយោងតាមមជ្ឈមណ្ឌលព័ត៌មានជាតិរបស់ប្រព័ន្ធបម្រុងសហព័ន្ធដោយផ្តោតសំខាន់ទៅលើការដាក់ប្រាក់ លទ្ធភាពសម្រាប់អ្នកដាក់បញ្ញើ ផ្តល់ប្រាក់កម្ចី និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗទៀត។

## ៣.២.អតិថិជនគោលដៅ

**រូបវន្តបុគ្គល**

- មានសិទ្ធប្រកបការងារតាមផ្លូវច្បាប់ ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ
- រស់នៅជាអចិន្ត្រៃយ៍ក្នុងតំបន់ប្រតិបត្តិការរបស់ធនាគារដោយមានការបញ្ជាក់បីអាជ្ញាធរមូលដ្ឋានដូចជាអត្តសញ្ញាណប័ណ្ណ សំបុត្របញ្ជាក់កំណើត។ល។
- មានមុខរបរឬចំណូលដើម្បីបង្ហាញពីលទ្ធភាពនៃការសងត្រឡប់
- មិនជាប់ពិរុទ្ធដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ
- មានប្រវត្តិល្អដែលអាចឲ្យធនាគារទុកចិត្តបាន។

**នីតិបុគ្គល**

- ក្រុមហ៊ុនត្រូវមានឈ្មោះ ទីតាំងច្បាស់លាស់ មានរចបាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ មានច្បាប់អាជីវកម្ម មានអាជ្ញាប័ណ្ណដែលបញ្ជាក់ពីភាពស្របច្បាប់
- ជាក្រុមហ៊ុនដែលមានអាជីវកម្មកំពុងដំណើរការ មានភាពរឹងមាំ និងមានប្រាក់ចំណេញ
- មានរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវ

## ៣.៣. សារៈសំខាន់នៃការគ្រប់គ្រង

ធនាគារពាណិជ្ជដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចទាំងនៅថ្នាក់ជាតិ និងពិភពលោក។ សារៈសំខាន់នៃប្រតិបត្តិការធនាគារពាណិជ្ជរួមមានការពិតដែលថាពួកគេបម្រើសេវាកម្មនិងជាកន្លែងដែលគួរឲ្យទុកចិត្តនិងមានសុវត្ថិភាព។ នៅលើឆាកអន្តរជាតិធនាគារពាណិជ្ជដើរតួជាប្រភពនៃការផ្ទេរប្រាក់ពីប្រទេសមួយទៅប្រទេសមួយដោយលុបបំបាត់នូវតម្រូវការក្នុងការធ្វើដំណើរជាមួយប្រាក់។ ប្រាក់ដែលបង់ដោយអ្នកដាក់

ប្រាក់បញ្ញើទៅក្នុងគណនីសន្សំរបស់ពួកគេក៏ត្រូវបានប្រើប្រាស់ដោយធនាគារដើម្បីជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈការផ្តល់ប្រាក់កម្ចីដល់អាជីវកម្ម និងបុគ្គលផ្សេងៗគ្នា។

សារៈសំខាន់នៃប្រតិបត្តិការធនាគារពាណិជ្ជរួមមានចំណុចសំខាន់ដូចជា៖

- ❖ ជួយអតិថិជនផ្សេងៗទាំងបុគ្គល និងអាជីវកម្មទិញរបស់របរដែលពួកគេមិនអាចមានលទ្ធភាពទិញដោយគ្មានជំនួយហិរញ្ញវត្ថុពីធនាគារ នេះរួមបញ្ចូលទាំងការទិញរថយន្ត ផ្ទះ និងរបស់របរប្រើប្រាស់ដែលមានដើមទុនច្រើនដូចជាគ្រឿងម៉ាស៊ីន ឬឧបក្ខារសម្រាប់ផលិត។
- ❖ ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការសងប្រាក់វិញតាមរយៈការរៀបចំផែនការហិរញ្ញវត្ថុរយៈពេលវែង ដែលប្រាក់នឹងត្រូវបានបែងចែកក្នុងរយៈពេលកំណត់ គុណសម្បត្តិគឺថានេះធ្វើឲ្យវាកាន់តែងាយ) ស្រួលសម្រាប់អ្នកខ្ចីក្នុងការសងប្រាក់វិញ ទោះបីជាពួកគេត្រូវបង់ការប្រាក់លើប្រាក់កម្ចីដែលជាប្រភេទនៃសេវាកម្មក៏ដោយ។(

## ៣.៤.នីតិវិធីនៃការគ្រប់គ្រងសេវាឥណទាន

### ៣.៤.១.ការដាក់ពាក្យសុំចុះឈ្មោះខ្ចីឥណទាន

- ❖ អ្នកដាក់ពាក្យសុំចុះឈ្មោះខ្ចីមកជួបផ្ទាល់ជាមួយភ្នាក់ងារបម្រើសេវាអតិថិជននៅការិយាល័យរបស់ធនាគារពាណិជ្ជ
- ❖ ភ្នាក់ងារបម្រើអតិថិជនធ្វើការពន្យល់ពីគោលការណ៍ នីតិវិធីឥណទាន តម្រូវការសម្រាប់ធនាគារ និងលក្ខខណ្ឌក្នុងការខ្ចីឥណទានតម្រូវឱ្យបានច្បាស់លាស់ទៅអ្នកសុំចុះឈ្មោះខ្ចី
- ❖ ភ្នាក់ងារបម្រើអតិថិជនផ្តល់ពាក្យសុំចុះឈ្មោះខ្ចីជូនទៅអតិថិជននិងប្រាប់អំពីឯកសារតម្រូវសម្រាប់ធនាគារ
- ❖ ប្រសិនបើពាក្យនៅមានការខ្វះចន្លោះ ភ្នាក់ងារត្រូវជួយបំពេញបន្ថែម
- ❖ ក្រោយពីទទួលបានពាក្យចុះឈ្មោះខ្ចីរបស់អតិថិជនដែលបានបំពេញត្រឹមត្រូវនិងបានត្រួតពិនិត្យរួចរាល់ហើយ ភ្នាក់ងារបម្រើអតិថិជនត្រូវដាក់ពាក្យនោះក្នុងឯកសាររបស់ភ្នាក់ងារឥណទានដែលទទួលបន្ទុក ឬក៏អ្នកដាក់ពាក្យស្នើសុំអាចទំនាក់ទំនងដោយផ្ទាល់ទៅកាន់ភ្នាក់ងារដែលបានចុះទៅមូលដ្ឋានផ្ទាល់របស់ខ្លួន។

### ៣.៤.២.ការចុះអង្កេត និងវាយតម្លៃ

ការចុះអង្កេតត្រូវអង្កេតលើ៖

- ➢ ចរិកលក្ខណៈ:មន្ត្រីឥណទានត្រូវតែមានការជឿជាក់លើអតិថិជនថាមានគោលដៅច្បាស់លាស់ក្នុងការស្នើសុំឥណទានហើយមានគោលបំណងសងត្រឡប់មកវិញយ៉ាងពិតប្រាកដ

➢ សមត្ថភាពៈមន្ត្រីឥណទានត្រូវតែច្បាស់លាស់ថាអតិថិជននោះមានសិទ្ធិសុំខ្ចីឥណទានហើយក៏មានសិទ្ធិជាផ្លូវច្បាប់ក្នុងការចុះហត្ថលេខាលើកិច្ចសន្យាឥណទាន

➢ សាច់ប្រាក់:អ្នកខ្ចីអាចមានលទ្ធភាពដើម្បីបង្កើតសាច់ប្រាក់បានដែរឬទេក្នុងការសងឥណទានត្រឡប់មកវិញ

ជាទូទៅអតិថិជនដែលស្នើសុំឥណទានមានប្រភពសាច់ប្រាក់៣ដែលអាចសងត្រឡប់មកវិញគឺ

- សាច់ប្រាក់ដែលទទួលបានពីចំណូលនិងការលក់
- សាច់ប្រាក់ដែលកើតចេញពីការលក់ទ្រព្យសកម្ម
- មូលធនដែលបានមកពីការបោះផ្សាយនូវមូលបត្របំណុល

➢ ទ្រព្យបញ្ចាំៈក្នុងការវាយតម្លៃទ្រព្យបញ្ចាំរបស់អ្នកស្នើសុំឥណទាន មន្ត្រីឥណទានត្រូវវិភាគឲ្យបានល្អិតល្អន់ទៅលើៈ

- ចំណូល

⇨ ចំណូលប្រចាំថ្ងៃពីអាជីវកម្មរបស់អតិថិជន ភាគច្រើនអតិថិជនជំពាក់បំណុលសឹងតែយកប្រាក់ចំណូលសងវិញ

⇨ ធ្វើការវាយតម្លៃកាតព្វកិច្ចនៃប្រាក់ចំណូលនោះទៅលើក្រុមគ្រួសារនិងកាតព្វកិច្ចនៃចំណាយផ្សេងៗទៀតដូចជា កាតព្វកិច្ចអាហារកិច្ច ចំណាយប្រចាំថ្ងៃជាដើម

- ភាពជំពាក់បំណុលនិងការចំណាយ

វាជាផ្នែកមួយដ៏សំខាន់ក្នុងការស៊ើបអង្កេតព្រោះវាពាក់ព័ន្ធនឹងការលាតត្រដាងនូវចំនួនសរុបរបស់ចំណូល ចំនួនសំណង និងរាល់កាតព្វកិច្ចផ្សេងទៀតដែលធ្វើឲ្យលំហូរនៃចំណូលមិនអាចគ្រប់គ្រងបាន

- ការងារ

⇨ ឈ្មោះបុគ្គលិក ប្រវត្តិរូបសង្ខេប ប្រភេទនៃការងារ មុខតំណែង រយៈពេលនៃការធ្វើការ ចំនួនប្រាក់បៀវត្សនិងស្ថេរភាពនៃការងារ

⇨ ពត៌មានតែងតែប្រមូលបានពីរបាយការណ៍ពន្ធលើប្រាក់ចំណូលជាមួយនឹងការអនុញ្ញាតពីគណនេយ្យករដែលមានមុខងារពាក់ព័ន្ធនឹងការរក្សាបញ្ជី

- ការរស់នៅ

⇨ ស្រាវជ្រាវលើការរស់នៅត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណកម្មឲ្យបានច្បាស់លាស់

⇨ រយៈពេលនៃការរស់នៅក្នុងតំបន់បច្ចុប្បន្ននិងពីមុនត្រូវកំណត់ស្ថិតនៅក្នុង៣ទៅ៥ឆ្នាំចុងក្រោយ

⇨ ការស៊ើបអង្កេតអាចបញ្ជាក់ថាអ្នកស្នើសុំជាម្ចាស់ឬជួលនូវអចលនទ្រព្យនេះ

⇨ កំណត់ចំនួនទឹកប្រាក់នៃការជួលនិងរបៀបសង ប្រសិនបើអចលនទ្រព្យនេះជួល

- ស្ថានភាពគ្រួសារ

⇨ ស្ថានភាពប្តីប្រពន្ធសម្រាប់ប្រើប្រាស់ក្នុងការពិចារណាលើគុណសម្បត្តិសំខាន់ៗក្នុងប្រតិបត្តិការនៃការប្រើប្រាស់ឥណទាន

⇨ ការសួរអំពីការចុះហត្ថលេខារួមពីគូរស្រករទៅលើសំណើឥណទានស្របតាមច្បាប់រដ្ឋត្រឹមត្រូវដែលតម្រូវឱ្យពាក់ព័ន្ធលើសិទ្ធិរក្សាទ្រព្យសម្បត្តិរបស់កូនបំណុល បណ្តឹងរឹបអូសពីតតិយជនឬការវាយតម្លៃស្ថានភាពប្រាក់ឈ្នួល

- អាយុ

⇨ អ្នកស្នើសុំគួរគ្រប់អាយុតាមផ្លូវច្បាប់ទើបមានសិទ្ធិចុះហត្ថលេខាលើកិច្ចសន្យាជាមួយនឹងការស៊ើបអង្កេតជាច្រើន ដោយអាយុមិនសំខាន់សម្រាប់គុណសម្បត្តិឥណទានទេ ប៉ុន្តែទោះយ៉ាងណាក៏ដោយនៅតែប្រកាន់យកយុវភាពនិងអាយុមានសារៈសំខាន់ចាំបាច់សម្រាប់ឥណទានដែរ

⇨ ជាទូទៅហានិភ័យឥណទានថយចុះជាមួយកំណើនអាយុ ជាពិសេសអាយុប្រហែល៥០ឆ្នាំឡើងទៅ

### ៣.៤.៣.ការអនុម័តឥណទាន

ក្រោយពីស៊ើបអង្កេតរួចរាល់ហើយភ្នាក់ងារឥណទានត្រូវបញ្ជូនឯកសារខ្ចីប្រាក់ដែលបានរៀបចំរួចហើយដាក់ជូនមកអ្នកគ្រប់គ្រងដែលមានសិទ្ធិអនុម័តឥណទានដើម្បីសុំការផ្តល់យោបល់លើសំណើសុំអនុម័តឥណទានពីគណៈកម្មាធិការឥណទានប្រចាំសាខារួចធ្វើការអង្កេតបន្ថែមដើម្បីអនុម័ត ប្រសិនបើឥណទានលើសពីការសម្រេចរបស់សាខាត្រូវបញ្ជូនបន្តទៅការិយាល័យកណ្តាលដើម្បីឲ្យគណៈកម្មាធិការវាយតម្លៃនិងសម្រេចរួចបញ្ជូនបន្តមកប្រធានផ្នែកឥណទានប្រចាំសាខាវិញដើម្បីផ្តល់ចម្លើយទៅភ្នាក់ងារអំពីការសម្រេចផ្តល់ឥណទាន។

### ៣.៤.៤.ការរៀបចំឯកសារ

បន្ទាប់ពីអនុម័តរួច ភ្នាក់ងារឥណទានត្រូវចុះទៅលំនៅដ្ឋានរបស់អតិថិជនជាលើកទី២ ដើម្បីធ្វើកិច្ចព្រមព្រៀងដែលរួមមាន កិច្ចព្រមព្រៀងឥណទាន កិច្ចព្រមព្រៀងដាក់វត្ថុបញ្ចាំ និងឯកសារដែលពាក់ព័ន្ធ។ មន្ត្រីឥណទានដែលទទួលខុសត្រូវទាំងស្រុងក្នុងការរៀបចំឯកសារនិងបញ្ជាក់ឲ្យច្បាស់នូវអត្តសញ្ញាណដែលមិនត្រឹមត្រូវ។ បន្ទាប់ពីឯកសារបានចុះហត្ថលេខាឬផ្តិតមេដៃទល់មុខមន្ត្រីឥណទានហើយ អតិថិជនត្រូវយកឯកសារទាំងនោះបញ្ជូនទៅអាជ្ញាធរដែនដីដោយខ្លួនឯងផ្ទាល់ដើម្បីបោះត្រានិងធ្វើការបញ្ជាក់។ បន្ទាប់ពីឯកសារមានការពេញលេញហើយមន្ត្រីឥណទានត្រូវបញ្ជូនឯកសារទាំងនោះទៅបេឡាករនិងជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំនូវ

កាលបរិច្ឆេទដែលដាក់លាក់ដើម្បីទទួលបានប្រាក់។ បេឡាករបង្ហាញនូវគ្រប់ឯកសាររួមមាន តារាងកាលវិភាគសងប្រាក់ និងរួមទាំងប័ណ្ណបញ្ចេញឥណទានផងដែរ។ បន្ទាប់មកគណនេយ្យករត្រូវពិនិត្យឯកសារនិងបង្ហាញវិក័យប័ត្រដាក់ទ្រព្យបញ្ចាំនិងបញ្ជូនទៅប្រធានមន្ត្រីឥណទានសាខាដើម្បីធ្វើការអនុម័ត។

### ៣.៤.៥.ការបញ្ចេញឥណទាន

ក្រោយពីរៀបចំឯកសាររួចហើយ ឯកសារទាំងនោះត្រូវបញ្ជូនទៅកាន់បេឡាករសាច់ប្រាក់ដោយបេឡាករត្រូវតែរៀបចំឲ្យរួចរាល់នៅថ្ងៃដែលអតិថិជនមកដល់។ នៅកាលបរិច្ឆេទបញ្ចេញសាច់ប្រាក់ អតិថិជនត្រូវទៅជួបនឹងបេឡាករ បន្ទាប់មកបេឡាករត្រូវពន្យល់ចំណុចសំខាន់ៗរួមមាន វិធីសាស្ត្រសងត្រឡប់ ប្រាក់ពិន័យ និងត្រូវប្រាប់អតិថិជនឲ្យធ្វើការរាប់នូវចំនួនទឹកប្រាក់មុនពេលចាកចេញ និងមិនអាចទាមទារបានទេនៅពេលដែលបានចាកចេញពីការិយាល័យហើយ។

### ៣.៤.៦.ការតាមដានប្រាក់សំណងនិងការប្រមូលសំណង

- ភ្នាក់ងារឥណទានត្រូវធ្វើការតាមដាននូវការសងប្រាក់របស់អតិថិជនតាមរយៈរបាយការណ៍ដែលបានបោះផ្សាយ
- ក្នុងករណីដែលអតិថិជនបានមកទូទាត់តាមកាលកំណត់នោះបេឡាករនឹងធ្វើការកត់ត្រានូវចំនួនសងក្នុងសៀវភៅឥណទានរួចចេញប័ណ្ណទទួលប្រាក់ជូនអតិថិជនដោយមានការផ្តិតមេដៃរបស់អតិថិជនលើប័ណ្ណទទួលប្រាក់នោះផងដែររួចធ្វើការបញ្ជាក់អំពីថ្ងៃសងត្រឡប់បន្ទាប់ទៅកាន់អតិថិជន
- ក្នុងករណីដែលអតិថិជនមិនមកទូទាត់តាមកាលកំណត់នោះទេ បេឡាករធ្វើរបាយការណ៍ពីអតិថិជនមិនមកទូទាត់ រួចផ្តល់របាយការណ៍នោះទៅកាន់មន្ត្រីឥណទានដែលទទួលខុសត្រូវ រួចហើយមន្ត្រីឥណទានត្រូវចុះជួបអតិថិជនផ្ទាល់ដល់លំនៅដ្ឋានឬទីតាំងអាជីវកម្មដើម្បីឲ្យអតិថិជនមកបង់ប្រាក់ដល់ការិយាល័យ
- ចំពោះទឹកប្រាក់ដែលមន្ត្រីឥណទានប្រមូលបានពីអតិថិជនត្រូវប្រគល់ឲ្យបេឡាករនិងធ្វើការកាត់សងឥណទាននៅក្នុងថ្ងៃដដែល

### ៣.៤.៧.ការយកឥណទានសារឡើងវិញ

ការយកឥណទានសារឡើងវិញបានអាចធ្វើទៅបាននៅពេលដែលឥណទានចាស់បានបញ្ចប់។ ដោយបេឡាករផ្តល់ជូនពាក្យស្នើសុំខ្ចីឥណទានថ្មីទៅអតិថិជនដើម្បីបំពេញនិងចុះហត្ថលេខា ក្រោយពីបំពេញបានត្រឹមត្រូវរួចរាល់ហើយត្រូវបញ្ជូនដោយផ្ទាល់ទៅគណនេយ្យករ។ គណនេយ្យករបោះពុម្ពរបាយការណ៍សងប្រាក់និងបញ្ជូនទៅជំនួយការរដ្ឋបាល រួចរបាយការណ៍នោះត្រូវបានបញ្ជូនទៅមន្ត្រីឥណទានដែលទទួលបន្ទុកដើម្បីផ្តើមដំណើរការពីដំណាក់កាលទី២។ នីតិវិធីនៃការបញ្ចេញឥណទានត្រូវបានធ្វើតាមមួយដំណាក់កាលម្តងៗ

ដោយនៅដំណាក់កាលបញ្ចេញឥណទានអាចធ្វើតាមក្រោយឬអាចធ្វើដំណាលគ្នាជាមួយនឹងការងារផ្សេងៗ ប៉ុន្តែត្រូវប្រាកដថាមុនពេលបញ្ចេញឥណទានឯកសារទាំងអស់ត្រូវបានបំពេញនិងត្រឹមត្រូវតាមគោលដៅ។

### ៣.៤.៨.ការគ្រប់គ្រងស្ថានភាពរបស់ឥណទានមានបញ្ហា

សូចនាករបស់ឥណទានមានបញ្ហា៖

- ការទូទាត់ឥណទានមិនទៀងទាត់
- ការផ្លាស់ប្តូរលក្ខខណ្ឌឥណទានជាញឹកញាប់
- ការកត់ត្រាការចាប់ផ្តើមថ្មីនៃឥណទានខ្សោយ(ប្រាក់ដើមកាត់បន្ថយបន្តិចម្តងៗតាមពេលនីមួយៗ) ឥណទានត្រូវបានគេចាប់ផ្តើមថ្មី។
- អត្រាឥណទានខ្ពស់មិនប្រក្រតី
- ការកើនឡើងមិនរំពឹងទុក នៃគណនីឥណទេយ្យរបស់អ្នក ខ្ចីប្រាក់ និងសន្និធិ
- អនុបាតបំណុលចំពោះតម្លៃពិតកើនឡើង(អានុភាព)
- ឯកសារបាត់បង់ជាពិសេស ការបាត់បង់របាយកា)រណ៍ហិរញ្ញវត្ថុរបស់អតិថិជន(
- វត្ថុបញ្ចាំមានគុណភាពអន់
- សេចក្តីទុកចិត្តលើរង្វាយតម្លៃរបស់ទ្រព្យសកម្ម ចំពោះការកើនឡើងតម្លៃពិតរបស់កម្ចីអតិថិជន
- អវត្តមានរបស់របាយការណ៍ចលនាសាច់ប្រាក់ ឬការកំរត់បង្ហាញផ្សេងៗ
- ការទុកចិត្តរបស់អតិថិជនលើប្រភពកើនឡើងយ៉ាងឆាប់រហ័សរបស់មូលនិធិដើម្បីជួបការទូទាត់ឥណទាន។

## ៣.៥.រូបិយប័ណ្ណ ទំហំឥណទាន និងអត្រាការប្រាក់

❖ **រូបិយប័ណ្ណ**

ចំពោះសេវាឥណទាន ធនាគារពាណិជ្ជផ្តល់ជូនអតិថិជនទាំងអស់ក្នុងទម្រង់ជា ប្រាក់រៀល ប្រាក់ដុល្លារ និងប្រាក់បាត។

❖ **ទំហំឥណទាន**

ចំពោះសេវាឥណទានរបស់ធនាគារពាណិជ្ជអតិថិជនអាចទទួលបានកម្ចីក្នុងទំហំរហូតដល់ ៣០០,០០០ដុល្លារ។

❖ **អត្រាការប្រាក់**

ចំពោះអត្រាការប្រាក់ ធនាគារពាណិជ្ជគិតចំពោះអតិថិជនក្នុងទំហំអតិបរមា១៨% ដោយអាស្រ័យទៅតាមប្រភេទឥណទាន រយៈពេល និងប្រភេទរូបិយប័ណ្ណដែលអតិថិជនជ្រើសយក។

## ៣.៦.របៀបសងត្រឡប់

ធនាគារពាណិជ្ជអនុញ្ញាតឲ្យអតិថិជនធ្វើការសងត្រឡប់មកវិញតាមរបៀប៖

- ❖ សងរំលស់ប្រាក់ដើមបូកការប្រាក់ថេរ(Annuity)ជារៀងរាល់ខែ
- ❖ សងការប្រាក់និងប្រាក់ដើមរំលស់(Linear)ជារៀងរាល់ខែ
- ❖ សងការប្រាក់រៀងរាល់ខែ រីឯប្រាក់ដើមសងតាមការព្រមព្រៀង
- ❖ សងការប្រាក់ ចំណែកប្រាក់ដើមសងចុងគ្រា
- ❖ សងការប្រាក់ រីឯប្រាក់ដើមគិតជាភាគរយ

## ៣.៧.ការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន

### ៣.៧.១.ការធ្វើចំណាត់ថ្នាក់ឥណទាន

ការធ្វើចំណាត់ថ្នាក់ឥណទាន គ្រប់ប្រភេទឥណទានទាំងអស់ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកទៅលើសមត្ថភាពសងរបស់អ្នកខ្ចី។ សមត្ថភាពសងនេះ ត្រូវបានវាយតម្លៃតាមរយៈ លក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ➢ ប្រវត្តិនៃការទូទាត់សង
- ➢ ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- ➢ គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- ➢ លទ្ធភាព និងឆន្ទៈក្នុងការសងត្រលប់មកវិញរបស់អ្នកខ្ចី
- ➢ បរិស្ថានហិរញ្ញវត្ថុ
- ➢ គុណភាពក្នុងការរៀបចំឯកសារ

ក្នុងករណីប្រភពដំបូងនៃការទូទាត់មិនសងអាចធានាបានចំពោះការទូទាត់សង ឥណទាន អាចត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬមិនដំណើរការ ទោះបីជាឥណទាននោះមាន លក្ខណៈចរន្ត ឬអាចនឹងត្រូវទូទាត់ដោយវត្ថុនានាក៏ដោយ។ ការធ្វើចំណាត់ថ្នាក់ឥណទានឡើងវិញក៏អាចធ្វើផងដែរ ប្រសិនបើអ្នកខ្ចីមិនអាចបំពេញតាមលក្ខខណ្ឌដើមនៃការទូទាត់សង ឬបើឥណទានមិនដំណើរការនោះ ត្រូវបានដោះស្រាយដោយបច្ចេកទេសនៃការផ្លាស់ប្តូរលក្ខខណ្ឌ មុនហិរញ្ញប្បទាន ឬបុរេប្រទានបន្ថែម៕

ក្នុងករណីដែលធ្វើចំណាត់ថ្នាក់នីមួយៗនៃឥណទាន ផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យមិនច្បាស់លាស់ ការធ្វើចំណាត់ថ្នាក់ដ៏តានតឹងជាងនេះត្រូវអនុវត្ត។ ករណីដែលវិភាគស្ថានភាពហិរញ្ញវត្ថុ សមត្ថភាព និងឆន្ទៈសងត្រលប់មកវិញរបស់អ្នកខ្ចីបានបង្ហាញឲ្យឃើញថា មានស្ថានភាពធ្ងន់ធ្ងរនោះចំណាត់ថ្នាក់ឥណទានត្រូវធ្វើឡើង

ឲ្យកាន់តែមានភាពតឹងរឹងបន្ថែមទៀត។

ចំណាត់ថ្នាក់ឥណទាន ត្រូវបែងចែកកជា៥ប្រភេទ ដូចតទៅៈ

| ចំណាត់ថ្នាក់ | ប្រភេទ | ចំនួនថ្ងៃយឺត | សំវិធានធន |
|---|---|---|---|
| ១ | ស្តង់ដា | ០-២៩ថ្ងៃ | ១% |
| ២ | ឃ្លាំមើល | ៣០-៨៩ថ្ងៃ | ៣% |
| ៣ | ក្រោមស្តង់ដា | ៩០-១៧៩ថ្ងៃ | ២០% |
| ៤ | សង្ស័យ | ១៨០-៣៥៩ថ្ងៃ | ៥០% |
| ៥ | បាត់បង់ | ៣៦០ឡើងទៅ | ១០០% |

➢ឥណទានរៀបចំឡើងវិញ

- ការរៀបចំឥណទានឡើងវិញ អាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណាដែលមានដំណើរការអាជីវកម្មល្អនាពេលខាងមុខហើយដែលកំពុងជួប ឬរំពឹងថានឹងជួបការលំបាកជាបណ្តោះ អាសន្នក្នុងការសងត្រឡប់មកវិញនូវប្រាក់ដើម និងឬ ការប្រាក់។/
- ត្រូវបានហាមឃាត់ចំពោះការអនុវត្តរៀបចំឥណទានឡើងវិញ ដោយគ្រាន់តែក្នុងគោល បំណងជៀសវាងៈ
    - ❖ ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន ឬ
    - ❖ ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់ ឬ
    - ❖ បញ្ឈប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ
- ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និង សមត្ថភាពសងប្រាក់ត្រឡប់វិញរបស់អ្នកខ្ចី តាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែល ស្របតាមស្ថានភាពទីផ្សារ និងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើ សម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន។
- ការរៀបចំឥណទានឡើងវិញ ត្រូវធ្វើឡើងដោយក្រុមការងារឯករាជ្យមួយ ដាច់ដោយឡែក ពីសាខាដែលពាក់ព័ន្ធនឹងការផ្តល់ឥណទាន។
- បន្ទាប់ពីឥណទានបានរៀបចំឡើងវិញ ធនាគារត្រូវធ្វើចំណាត់ថ្នាក់ឥណទាននោះដូចខាងក្រោមៈ
    - ❖ មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនត្រូវបានចាត់ថ្នាក់ជាសង្ស័យ ឬ បាត់បង់
    - ❖ មិនផ្លាស់ប្តូរ សម្រាបឥណទានដែលពីមុនមក ត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា ឃ្លាំ មើល ឬក្រោមស្តង់ដារ។៖

ការធ្វើចំណាត់ថ្នាក់នេះ មិនត្រូវឱ្យល្អជាងមុនឡើយ លុះត្រាតែការប្រាក់ និងប្រាក់ដើមត្រូវ បានសងមក វិញក្នុងអំឡុងបីគ្រាសងរំលស់ និងក្នុងរយៈពេលមិនតិចជាងបីខែ។ បន្ទាប់ពីរយៈពេល នេះឥណទានដែលត្រូវ បានរៀបចំឡើងវិញ អាចត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទចំណាត់ថ្នាក់ឥណទាន។

ការរៀបចំឯកសារសម្រាប់ឥណទានមាន៖

១.លិខិតសំណើសុំពីអតិថិជន

២.ទម្រង់ពាក្យស្នើសុំខ្ចីឥណទានដែលបានបំពេញរួចរាល់

៣.កំណត់ហេតុវាយតម្លៃទ្រព្យធានា ក្នុងករណីការផ្លាស់ប្តូរអ្នកធានា និង/ឬ អាស័យដ្ឋាន

៤.របាយតារណ៍ការិយាល័យឥណទានកម្ពុបាដែលបានធ្វើបច្ចុប្បន្នកម្ម

៥.របាយការណ៍ធនាគារសម្រាប់រយៈពេល ១២ខែចុងក្រោយ

៦. ឯកសារភស្តុតាងពីកំរៃសេវា ។

**៣.៧.២.ការធ្វើសំវិធានធន**

ធនាគារត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឲ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការ ខាតបង់ក្នុង សំពាធឥណទានដែលអាចកើតឡើង៕

សំវិធានធនមាន២ប្រភេទ គឺសំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

**សំវិធានធនសរុប= សំវិធានធនទូទៅ + សំវិធានធនជាក់លាក់**

- សំវិធានធនទូទៅ
  - សម្រាប់ឥណទានថ្នាក់(ធម្មតា): ១%នៃឥណទានដុល
- សំវិធានធនជាក់លាក់
  - សម្រាប់ឥណទានថ្នាក់(ឃ្លាំមើល): ៣%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់ (ក្រោមស្តង់ដា): ២០%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់(សង្ស័យ): ៥០%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់(បាត់បង់): ១០០%នៃឥណទានដុល
- ធនាគារត្រូវរក្សាការកត់ត្រាឲ្យបានត្រឹមត្រូវ ដើម្បីជាការគាំទ្រដល់ការវាយតម្លៃ ឥណទានដែលបាន បាត់បង់ និងការធ្វើសំវិធានធនឲ្យបានគ្រប់គ្រាន់សម្រាប់ឥណ ទានបាត់បង។
- សំវិធានធនជាក់លាក់ ត្រូវកត់ត្រាក្នុងគណនីរបស់ធនាគារ ហើយចាតទុកជាចំណាយនៅក្នុងរបាយ ការណ៍ចំណេញខាតនៅក្នុងគ្រាដែលត្រូវធ្វើសំវិធានធននោះ។ សំវិធានធន-មិនត្រូវបានរំលស់នៅតាម គ្រានោះទេ។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់

ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ជាមួយការព្យួរទុកមូលធនកម្មការប្រាក់នេះមិនត្រូវយកមក គិតសម្រាប់គណនីសំវិធានធនទេ។

## ៣.៨.ហានិភ័យឥណទាន

### ៣.៨.១.មូលហេតុដែលនាំឲ្យមានហានិភ័យ

**ក.កត្តាអតិថិជន**

- អតិថិជនមានចេតនាមិនសងប្រាក់ត្រឡប់
- ការប្រើប្រាស់ឥណទានខុសគោលដៅ
- មានបញ្ហាក្នុងមុខរបរនិងអាជីវកម្ម
- ការផ្លាស់ប្តូរទីលំនៅ
- អតិថិជនមានប្រវត្តិលេងល្បែងស៊ីសង និងអំពើអបាយមុខផ្សេងៗបណ្តាលឲ្យបាត់បង់ទ្រព្យសម្បត្តិ
- អ្នករួមវិនិយោគបោកប្រាស់ តាមរយៈការកេញប្រវ័ញ្ចលើប្រាក់ចំណេញនៃមុខរបរ
- អតិថិជនមានទំនាស់ក្នុងគ្រួសារ ការបែកបាក់គ្រួសារដែលជាហេតុនាំឲ្យសមាជិកគ្រួសារគ្មានទំនួល ខុសត្រូវក្នុងការសង

**ខ.កត្តាគ្រឹះស្ថាន**

- ការវាយតម្លៃលើឥណទានពុំបានល្អិតល្អន់ និងយកចិត្តទុកដាក់
- ភ្នាក់ងារឥណទានមិនយកចិត្តទុកដាក់ក្នុងការប្រមូលពត៌មានអតិថិជន ឬក្លែងបន្លំពត៌មានជំនួស អតិថិជនដែលជាហេតុនាំឲ្យមានហានិភ័យឥណទាន
- ភ្នាក់ងារឥណទានមិនយកចិត្តទុកដាក់លើការវាយតម្លៃទ្រព្យធានា
- ភ្នាក់ងារឥណទានមិនយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យបំណុល។

**គ.កត្តាធម្មជាតិ និងសង្គម**

- មានសង្គ្រាម
- ការធ្លាក់ចុះនៃសេដ្ឋកិច្ច
- ការផ្លាស់ប្តូររបបនយោបាយ
- ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ។ល។

**ឃ.កត្តាកូវីត១៩**

- សេដ្ឋកិច្ចមានការធ្លាក់ចុះ
- ប្រជាពលរដ្ឋមានចំណូលទាប

- ចំនួនការងារត្រូវបានកាត់បន្ថយ
- អាជីវកម្មមួយចំនួនបានផ្អាកដំណើរការ
- មានការរាំងស្ទះដល់ការធ្វើពាណិជ្ជកម្ម
- ប្រជាពលរដ្ឋមានហានិភ័យក្នុងការឆ្លងជម្ងឺ។

### ៣.៨.២.វិធីសាស្ត្រកាត់បន្ថយហានិភ័យ

វាយតម្លៃអតិថិជនឲ្យបានត្រឹមត្រូវទៅលើ

- គោលបំណងនៃការសុំខ្ចី
- ពិនិត្យមើលលើអាជីវកម្មរបស់អ្នកសុំខ្ចី
- វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
- ពិនិត្យលើប្រវត្តិរូបរបស់អ្នកខ្ចី
- ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា

ពង្រឹងសមត្ថភាពបុគ្គលិក

- ជ្រើសរើសបុគ្គលិកដែលមានជំនាញខាងឥណទាន
- ធ្វើការបណ្ដុះបណ្ដាលបន្ថែមដល់បុគ្គលិកជាការចាំបាច់
- ដាក់ទោសទៅលើបុគ្គលិកដែលមានកំហុស
- លើកទឹកចិត្តរាល់បុគ្គលិកដែលធ្វើការងារបានល្អ។

### ៣.៨.៣.ដំណោះស្រាយចំពោះឥណទានមានបញ្ហា

ទោះបីធនាគារព្យាយាមការពារសុវត្ថិភាពប្រាក់ឱ្យខ្ចីយ៉ាងណាក៏ដោយ ក៏ប្រាក់ឱ្យខ្ចីខ្លះក្លាយ ទៅជាប្រាក់ឱ្យខ្ចីមានបញ្ហាដោយចៀសពុំរួច។

ជំហានសំខាន់ក្នុងការដោះស្រាយបំណុលមានបញ្ហាមានដូចខាងក្រោម៖

- ត្រូវចងចាំអំពីគោលបំណងនៃការធ្វើគម្រោងឥណទានគឺបង្កើនឱកាសសម្រាប់ស្ថាប័នក្នុងការ ប្រមូលបំណុល។
- រកឱ្យឃើញនិងរាយការណ៍ភ្លាមៗអំពីបញ្ហាដែលកើតមានចំពោះប្រាក់ខ្ចីគឺជាការសំខាន់ប្រសិន បើមានការយឺតយ៉ាវនឹងធ្វើឱ្យមានបញ្ហាកាន់តែលំបាក។
- បែងចែកការទទួលខុសត្រូវចំពោះការធ្វើគម្រោងឥណទាន ធ្វើឱ្យដាច់ចេញពីមុខងារឱ្យខ្ចី ដើម្បី ជៀសវាងទំនាស់ផលប្រយោជន៍ណាមួយដែលអាចកើតមានឡើងចំពោះមន្ត្រីឥណទាន ។

- អ្នកឯកទេសទទួលបន្ទុកផ្នែកធ្វើគំរោង គប្បីពិភាក្សាភ្លាមៗ ជាមួយអតិថិជនដែលមានបញ្ហា ស្តីអំពីវិធានការផ្សេង ដូចជាការកាត់បន្ថយចំណាយ ការបង្កើនលំហូរសាច់ប្រាក់ ការកែលំអការងារ គ្រប់គ្រង ជាដើម។
- ធ្វើផែនការអនុវត្តជាបឋមមួយក្រោយពេលបានកំណត់ហានិភ័យ និងនៅពេលមាន ឯកសារគ្រប់គ្រាន់
- ធ្វើការប៉ាន់ស្មានអំពីប្រភពដែលអាចប្រើប្រាស់ក្នុងការប្រមូលបំណុល
- បុគ្គលិកទទួលបន្ទុកធ្វើគម្រោងឥណទានគប្បីស្រាវជ្រាវតាមរយៈច្បាប់ និងពន្ធដើម្បីមើលក្រែង អ្នកខ្ចីប្រាក់មានបំណុលមិនទាន់សងផ្សេងទៀត។
- ក្នុងករណីជាក្រុមហ៊ុនជំនួញ បុគ្គលិកឥណទានត្រូវវាយតម្លៃពីគុណភាព សមត្ថភាព និងភាពស្មោះត្រង់នៃការងារគ្រប់គ្រងបច្ចុប្បន្ន និងចុះទៅផ្ទាល់នឹងកន្លែង ដើម្បីវាយតំលៃទ្រព្យសម្បត្តិ និងប្រតិបត្តិការរបស់អ្នកឱ្យខ្ចី។
- បុគ្គលិកទទួលបន្ទុកគម្រោងត្រូវពិចារណារកមធ្យោបាយផ្សេងៗ ដើម្បីដោះស្រាយបំណុលដែល មានបញ្ហា ដូចជាការធ្វើកម្ចីសន្យាថ្មីបណ្តោះអាសន្នមួយប្រសិនបើយល់ថា បញ្ហានេះអាចដោះស្រាយ បានក្នុងរយៈពេលមួយខ្លី។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តី និងការប្រមូលព័ត៌មានដែលទាក់ទងទៅនឹងប្រធានបទការគ្រប់គ្រងសេវាឥណទានរបស់ធនាគារពាណិជ្ជរួចមក យើងអាចធ្វើការសន្និដ្ឋានបានថាធនាគារពាណិជ្ជបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឲ្យមានភាពរីកចម្រើនជាងមុនតាមរយៈការផ្តល់នូវសេវាកម្មរបស់ខ្លួនជាពិសេសទាក់ទងទៅនឹងសេវាឥណទានដោយក្នុងនោះចំពោះ សេវាកម្មឥណទានធនាគារពាណិជ្ជបានប្រើប្រាស់នូវគោលការណ៍ និងនីតិវិធីក្នុងការផ្តល់ឥណទានរបស់ខ្លួនបានយ៉ាងត្រឹមត្រូវនិងកំណត់យ៉ាងច្បាស់លាស់ចំពោះតម្រូវការរបស់អតិថិជនដូចជាទំហំឥណទាន រយៈពេលសងត្រឡប់ របៀបនៃការសងត្រឡប់ និងអត្រាការប្រាក់សម្រាប់អតិថិជនដែលអាចទុកចិត្តនិងទទួលយកបាន។ ដោយមុនពេលផ្តល់ឥណទានទៅកាន់អតិថិជន ភ្នាក់ងាររបស់ធនាគារពាណិជ្ជបានធ្វើការសង្កេតនិងវាយតម្លៃយ៉ាងល្អិតល្អន់ទៅលើគោលបំណង មុខរបរ ចំណូល ចំណាយ និងទ្រព្យបញ្ចាំនានាដើម្បីវាស់វែងអំពីលទ្ធភាពនៃការសងត្រឡប់ដើម្បីកុំឲ្យមានហានិភ័យនៃការខាតបង់។ លើសពីនេះទៀតក្រោយពេលផ្តល់ឥណទានរួចភ្នាក់ងាររបស់ធនាគារពាណិជ្ជ ក៏ត្រូវត្រួតពិនិត្យលើសកម្មភាពរបស់អតិថិជនក្នុងការប្រើប្រាស់នូវឥណទានដែលបានខ្ចីបានប្រើប្រាស់ដូចគោលបំណងដែលបានស្នើសុំនិងដើម្បីមានលទ្ធភាពក្នុងការសងត្រឡប់មកវិញ។

សរុបមកឃើញថាការគ្រប់គ្រងសេវាឥណទានរបស់ធនាគារពាណិជ្ជពិតជាមានភាពល្អប្រសើរ និងទទួលបានការទុកចិត្តយ៉ាងខ្លាំងពីសំណាក់អតិថិជន ដូចនេះហើយទើបធ្វើឲ្យធនាគារពាណិជ្ជបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យមានភាពងាយស្រួលជាងមុន ក៏ដូចជាចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។

## ២.អនុសាសន៍

តាមរយៈកិច្ចការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពីធនាគារពាណិជ្ជដែលក្នុងនោះបានស្វែងយល់ពីដំណើរការនៃការគ្រប់គ្រងសេវាកម្មឥណទាន និងសេវាកម្មប្រាក់បញ្ញើគឺប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធិផលជាពិសេសទទួលបានការគាំទ្រនិងទុកចិត្តពីអតិថិជនកាន់តែច្រើន។ ទន្ទឹមនឹងនេះដែរក្រុមយើងខ្ញុំក៏មាននូវមតិយោបល់ខ្លះៗសម្រាប់ធនាគារពាណិជ្ជដូចជា៖

- ❖ ធនាគារពាណិជ្ជត្រូវធ្វើការផ្សព្វផ្សាយនូវសេវាកម្មរបស់ខ្លួនឲ្យបានទូលំទូលាយជាងនេះបន្ថែមទៀតដើម្បីទាក់ទាញនូវចំណាប់អារម្មណ៍របស់អតិថិជនឲ្យកាន់តែច្រើន

❖ ធនាគារពាណិជ្ជគួរតែបន្ទាបអត្រាការប្រាក់សម្រាប់កម្ចី ដើម្បីលើកទឹកចិត្តដល់អតិថិជនដែលមានស្រាប់ឲ្យនៅបន្តការប្រើប្រាស់នូវសេវាកម្មរបស់ធនាគារបន្តទៀតក៏ដូចជាដើម្បីទាក់ទាញដល់អតិថិជនថ្មីឲ្យចូលមកប្រើប្រាស់នូវសេវាកម្មរបស់ធនាគារ

## ឯកសារយោង


❖ ប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន, លេខ ធ៧.០១៧.៣៤៤ ប្រ.ក, ០១ ធ្នូ ២០១៧

❖ ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខ ក៧.០៨.២១១ ប្រ.ក, ២៥ វិច្ឆិកា ២០០៨

❖ ប្រកាសស្តីពីដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, លេខ ធ៧.០១៦.១១៧ ប្រ.ក, ២២ មីនា ២០១៦

❖ ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារពាណិជ្ជ, លេខ ធ៧.០០.០៤ ប្រ.ក, ១០ មករា ២០០០

❖ ងួន ហេងនិងសាង សុមន្នី.២០១៩.រូបិយវត្ថុនិងធនាគារ. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

❖ ខឹម សារិទ្ធិ.២០១៨.ប្រតិបត្តិការនិងប្រព័ន្ធធនាគារកម្ពុជា. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យបៀលប្រាយ

❖ ឈាង ហ៊ុយ.២០១៩.ការគ្រប់គ្រងឥណទាន. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ៤

| Photo<br>4×6 |
|---|

**ជីវប្រវត្តិ និង ការសាកសួរនូវព័ត៌មាន អំពី**

**ឯកត្តជន ឬ ជនដែលបម្រុងក្លាយទៅជា: គណៈនាយក ភាគទុនិក**

**នាយកចាត់ការ របស់ធនាគារពាណិជ្ជ**

# CURRICULUM VITEA

**and**

**Questionnaire for individual who are, or are proposing to become,**

**<u>Directors, Shareholders of Commercial Banks</u>**

1. គោត្តនាម

Family name.

------------------------------------------------------------

2. នាមខ្លួន

Given name (s).

------------------------------------------------------------

3. ឈ្មោះហៅក្រៅ

Other name (s) by which you are or have been known.

------------------------------------------------------------

4-1. សូមរៀបរាប់បំពេញលើគំរូនេះនូវនិតិសម្បទារបស់លោក, ឧទាហរណ៍ដូចជា: គណៈនាយកបច្ចុប្បន្ន ឬជាអនាគតគណៈនាយក, ភាគទុនិក ឬនាយកចាត់ការ ឬបុគ្គលដែលមានលក្ខណៈប្រហាក់ប្រហែល។

Please state in what capacity you are completing this form, **i.e.** as a current or prospective director, shareholder or manager or any combination of these.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

4-2. សូមរៀបរាប់អំពីភារកិច្ច និងការទទួលខុសត្រូវណាមួយដែលទាក់ទងនឹងឋានៈតួនាទីទាំងនេះ

Please describe the particular duties and responsibilities attaching to the position(s).

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

4-3. ក្នុងការអនុវត្តន៍ភារកិច្ចរបស់អ្នក តើអ្នក និងសហប្រតិបត្តិការជាមួយ ឬយល់ស្របតាមការបង្គាត់បង្ហាញរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីបេក្ខជនដាក់ពាក្យសុំ។ ក្នុងករណីណាមួយក៏ដោយសូមផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធទាំងនេះ។

In carrying out your duties, will you act in concert with or in accordance with the instructions of another individual or legal person outside the applicant. In either case, give all relevant information.

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

4-4. សូមរៀបរាប់បើសិនជាអ្នក ជាអ្នកផ្តល់ទុនម្នាក់ទៅឱ្យបេក្ខជនដាក់ពាក្យសុំ ហើយបើសិនជាអ្នកមានបំណងចង់អនុវត្តដោយផ្ទាល់ ឬតាមរយៈអន្តរការីកម្មមួយ ឬផ្ទាល់ខ្លួន ឬជាប្រតិបត្តិការវិជ្ជាជីវៈជាមួយបេក្ខជនទាំងនេះ។

Indicate if you are a contributor of capital to the applicant and if you intend to carry out, directly or through an intermediary, personal or professional transactions with the applicant.

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

**5.** អាសយដ្ឋានផ្ទាល់ខ្លួន

Your private address.

..........................................................................................................................................................

..........................................................................................................................................................

**6.** អាសយដ្ឋានផ្ទាល់ខ្លួនដែលធ្លាប់បានរស់នៅកន្លងមក ចាប់ពីកំឡុង ៥ឆ្នាំមុន:

Your previous private address(es) during the last 5 years.

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

7. កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ) និងទីកន្លែងកើត (គិតទាំងស្រុកនិងក្រុង)

Your date(day/month/year) and place of birth (including district, town or city)

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..............................................................................................................................

8. សញ្ជាតិ ហើយតើសញ្ជាតិនោះត្រូវបានដោយរបៀបណា (កើតនៅទីនោះ, សញ្ជាតូបនីយកម្ម, ការរៀបអាពាហ៍ពិពាហ៍) ?

Your nationality and how it was acquired (birth, naturalization, marriage).

..............................................................................................................................

..............................................................................................................................

9. ឈ្មោះ និងអាសយដ្ឋាននៃធនាគារិករបស់លោក-លោកស្រី ក្នុងរយៈកាល ៥ឆ្នាំ កន្លងមក

Name(s) and address(es) of your bankers within the last 5 years.

..............................................................................................................................

..............................................................................................................................

..............................................................................................................................

10. ចូរបញ្ជាក់ពី កំរិតចំណេះដឹង និងគុណវុឌ្ឍិវិជ្ជាជីវៈ ព្រមទាំងទីកន្លែង និងឆ្នាំដែលបានទទួល

Your higher education and/or professional qualifications and the place and year they were obtained.

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

11-1. ចូររៀបរាប់អំពីមុខរបរ និងការងារដែលបានធ្វើក្នុងពេលបច្ចុប្បន្ន និងរយៈពេល១០ឆ្នាំ កន្លងមកដោយបញ្ជាក់ពីឈ្មោះ អាសយដ្ឋានរបស់និយោជកក្នុងករណីនិមួយៗ ចរិតនៃមុខជំនួញ, ស្ថានភាពដែលមាន និងកាលបរិច្ឆេទពាក់ព័ន្ធ។

Your occupation and employment now and during the **last 10 years,** including the name and address of the employer in each case, the nature of the business, the position held and relevant dates.

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

11-2. សូមរៀបរាប់កាលពី១០ឆ្នាំមុន បើសិនជាអ្នកជាភាគទុនិកដែលមានឈ្មោះកាន់កាប់ផ្ទាល់ ឬដោយប្រយោលនូវ ១០ភាគរយយ៉ាងតិចនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតនៃក្រុមហ៊ុនមួយក្រៅពីក្រុមហ៊ុនបច្ចុប្បន្ន បើសិនជាមានសូមរៀបរាប់ឈ្មោះ និងសកម្មភាពក្រុមហ៊ុននេះ និងចំនួនភាគហ៊ុន ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់អ្នកចំពោះក្រុមហ៊ុននេះ។

Indicate if you are or if you have been in the last ten years a significant shareholder (namely holding directly or indirectly at least 10% of the share capital or voting rights) other

than the applicant. If it is the case, the name and activities of such companies and the amount of your shareholding or interest in them.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**11-3** សូមរៀបរាប់ចំពោះការយល់ដឹងរបស់អ្នកចំពោះក្រុមហ៊ុនដែលអ្នកកាន់កាប់ឬបានកាន់កាប់ក្នុងការទទួលខុសត្រូវក្នុងតំណែងក្រុមហ៊ុនមួយជាភាគទុនិកសំខាន់មួយដែលមានទំនាក់ទំនងអាជីវកម្មជាមួយអ្នកដាក់ពាក្យសុំ។

State, to the best of your knowledge, which of the companies in which you have held or hold a position of responsibility, or in which you have been or are a significant shareholder, has or might soon have significant business relations with the applicant.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**12.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីរួមប្រាស្រ័យក្នុងឋានៈជានាយក, ជាភាគទុនិក ឬជាអ្នកចាត់ការធ្លាប់ទទួល ឬធ្លាប់ស្នើសុំអាជ្ញាប័ណ្ណ ឬធ្លាប់ចាត់ចែងសកម្មភាពជំនួញនៅក្នុងប្រទេសណាមួយដែរឬទេ, បើមានសូមបញ្ជាក់នូវចំណុចពិសេស ប្រសិនបើការស្នើនោះត្រូវបានបដិសេធ ឬត្រូវដកវិញបន្ទាប់ពីបានធ្វើហើយ ឬបាន ដកហូតការអនុញ្ញាតក៏ត្រូវបញ្ជាក់ចំណុចពិសេសដែរ។

Have your or any entity with which your are associated as a director, shareholder or manager, ever held or applied for a license or to carry on any business activity in any country? If so, give particulars, if any such application was refused or withdrawn after it was made or any authorization revoked, give particulars.

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

**13.** តើខ្លួនលោក-លោកស្រីផ្ទាល់ ឬអង្គភាពណាមួយដែលលោក-លោកស្រីបានពាក់ព័ន្ធ ជាមួយក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួន ធ្លាប់ត្រូវបានអាជ្ញាធរអាណាព្យាបាល ឬអង្គភាពវិជ្ជាជីវៈណាមួយព្រមានជាសាធារណៈ ឬជាកម្មវត្ថុដែលត្រូវ គេធ្វើការស៊ើបអង្កេតដែរឬទេ , បើមានសូមបញ្ជាក់។

Have you, or any entity with which you have been involved in the conduct of its affairs, been disciplined, warned as to future conduct, publicly criticized, or the subject of an investigation by any regulatory authority or any professional body? If so, give particulars.

--------------------------------------------------------------------------------------------------------

..............................................................................................................

..............................................................................................................

..............................................................................................................

14. តើលោក-លោកស្រី   ធ្លាប់បានបញ្ឈប់ពីការងារ ឬត្រូវបណ្តេញចេញពីការងារដោយនិយោជក ឬត្រូវគេហាមមិនឱ្យចូលប្រកបវិជ្ជាជីវៈជំនាញ ឬបម្រើការងារណាមួយដែរឬទេ, បើមានសូមបញ្ជាក់។

Have you, in any country, been dismissed from any office or employment by your employer or barred from entry to any professional or occupation? If so, give particulars.

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

15. តើធ្លាប់មានបញ្ហាដែលពាក់ព័ន្ធនឹងការកាត់ក្តីរបស់តុលាការពីការជំពាក់បំណុល   និងប្រាក់ដែលត្រូវសងគេដែរឬទេ   តើធ្លាប់មានប្រកាសស្តីពីការក្ស័យធនតាមលក្ខណៈគតិយុត្តិដែរឬទេ   នៅប្រទេសណា   តើធ្លាប់ទទួលរងការប្តឹងលើក្ស័យធនដែរឬទេ បើមានសូមបញ្ជាក់ក្នុងករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you failed to satisfy any debt adjudged due and payable by you under an order of a court, or have you been declared bankrupt by a court in any country or has bankruptcy petition ever been served on you? If so give particulars.

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

16. តើធ្លាប់មានពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពណាខ្លះ   ដែលត្រូវតុលាការកាត់សេចក្តីពីបទល្មើស,   នៅប្រទេសណា,  តើធ្លាប់បានទទួលខុសលើកំហុសណាខ្លះ   ឬការប្រព្រឹត្តិឆ្គាំឆ្គងផ្សេងៗ   ដែលមានចំពោះអង្គភាពណាមួយ ឬសមាជិកណាម្នាក់ដែរឬទេ, បើសិនជាមានសូមបញ្ជាក់ករណីនីមួយៗឱ្យបានច្បាស់លាស់។

Have you, in connection with the management of any entity been adjudged by a court, in any country, legally liable for any fraud, or other misconduct by you towards such an entity or towards any of its members? If so, give particulars.

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

17. បច្ចុប្បន្ននេះ  ក្រៅពីសមត្ថភាពវិជ្ជាជីវៈ  តើលោក-លោកស្រីមានការពាក់ព័ន្ធ  នឹងការប្តឹងផ្តល់នៅប្រទេសណាមួយ បើមានសូមបញ្ជាក់ឱ្យច្បាស់លាស់។

Are you presently, or do you, other than in a professional capacity, expect to be, engaged in any litigation in any country? If so, give particulars.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

18. សូមផ្តល់នូវរបាយការណ៍ត្រួតពិនិត្យ ស្តីពីមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ដោយផ្តល់នូវតារាងលំអិតស្តីពីទ្រព្យសកម្ម និង ទ្រព្យអកម្ម។

Please supply an **audited statement** of personal net worth providing a breakdown of your assets and liabilities.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

19. សូមបង្ហាញឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងតួនាទីឬកិត្តិនាម របស់ឯកត្តជនបីរូប ដែលត្រូវមានលក្ខណៈសម្បត្តិល្អ ដើម្បីបញ្ជាក់ពីលក្ខណៈបុគ្គល និងវិជ្ជាជីវៈរបស់សាមីខ្លួន (សាក្សីដឹងឮជាបុគ្គលដែលមិនមែនជាសាច់ញាតិ ហើយធ្លាប់បានស្គាល់លោក-លោកស្រីយ៉ាងតិច៥ឆ្នាំ)។

Indicate the names, addresses, telephone numbers and positions of three individuals of good standing who would be able to provide a reference on your personal and professional integrity. The referees must not be related to you, and should have known you for at least five years.

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

20. បើសិនជាមានព័ត៌មានបន្ថែមទៀតដែលសមស្របនឹងមុខងារ - តួនាទីផ្ទាល់ខ្លួនដូចមានបញ្ជាក់ក្នុងសំណួរ ៤-១. សាមីជនគួរតែបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ ដើម្បីជាគុណប្រយោជន៍សម្រាប់ការពិនិត្យ ពិចារណាឱ្យត្រឹមត្រូវតាមទម្រង់គតិយុត្តិ។ ករណីបំបាត់ចោលរាល់ព្រឹត្តិការណ៍រឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ដោយបង្វែរព័ត៌មានពិតឬផ្តល់ឱ្យនូវព័ត៌មានខុសពីការពិតនឹងត្រូវទទួលខុសត្រូវចំពោះច្បាប់ជាធរមាន

(សូមអានសេចក្តីប្រកាសដូចខាងក្រោម):

***ចូរកត់សម្គាល់ឱ្យបានច្បាស់ថា***: រាល់ព័ត៌មានដែលបានផ្តល់ឱ្យ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ហើយរាល់ព័ត៌មានទាំងនេះ ត្រូវបានរក្សាទុកជាសំងាត់ដោយអាជ្ញាធរគ្រប់គ្រង (ធនាគារជាតិនៃកម្ពុជា) លើកលែងតែករណីដែលផ្តល់ឱ្យស្របតាមទម្រង់គតិយុត្តិ។

Is there any additional information which you consider is relevant for the consideration of your suitability for the position(s) listed in Question 4.1? The omission of material facts may represent the provision of misleading information (see declaration below).
**N.B. (note well)** the information given in response to this questionnaire shall be kept fully confidential by the supervisory authority, the National Bank of Cambodia, except in cases provided for by law.

## សេចក្តីប្រកាស ឬកិច្ចសន្យាផ្ទាល់ខ្លួន

ខ្ញុំបាទសូមសន្យាថា នឹងទទួលខុសត្រូវនៅចំពោះមុខច្បាប់ បើសិនជាព័ត៌មានណាមួយដែលបានផ្តល់ជូននេះក្លែងក្លាយខុសពីការពិត ដែលពាក់ព័ន្ធនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថាន។ ខ្ញុំបាទសូមបញ្ជាក់ជូនជាឱឡារិកថា ព័ត៌មានដែលបានឱ្យជាចម្លើយ ចំពោះសំណួរខាងលើគឺពិតជាត្រឹមត្រូវ និងបានបំពេញបរិបូរណ៍ ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ឬនាងខ្ញុំ ហើយពិតជាមិនមានហេតុការណ៍ណាផ្សេង ឬផ្ទុយពីសេចក្តីរាយការណ៍ ដូចដែលបានបញ្ជាក់ជូនអាជ្ញាធរដែលគ្រប់គ្រង (សមត្ថកិច្ច) ដើម្បីជ្រាបនោះឡើយ។

ខ្ញុំបាទសូមសន្យាថា នឹងផ្តល់ព័ត៌មានជូនអាជ្ញាធរដែលគ្រប់គ្រងដើម្បីជ្រាបអំពី រឿងរ៉ាវ ឬហេតុការណ៍ ដែលត្រូវផ្លាស់ប្តូរណាមួយដែលកើតមាននៅពេលដែលអាជ្ញាធរគ្រប់គ្រងកំពុងពិនិត្យពិចារណាលើពាក្យស្នើសុំរបស់យើងខ្ញុំជ្រាបជាព័ត៌មាន។

**DECLARATION**

I am aware that it is an offense knowin or recklessly to provide any information which is false or misleading in connection with an application for a banking license or a renewal of bank license.
I certify that the information given in answer to the question above is complete and accurate to the best of my knowledge, and that there are no other facts relevant to this application of which the supervisory authority should be aware.
I undertake to inform the supervisory authority of any changes material to the application which arise while the supervisory authority is considering the application.

ឈ្មោះ
Name:

មុខងារ និងឋានៈដែលទទួលបន្ទុក
Position held:

ហត្ថលេខា ថ្ងៃ ខែ ឆ្នាំ
Signed: Date:……. /…….. / …….